ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការសកម្មភាពជាតិ
# ស្តីពី
# ការទប់ស្កាត់អំពើហិង្សាលើស្ត្រី
# ២០១៩-២០២៣

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០

រៀបចំដោយក្រសួងកិច្ចការនារី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការសកម្មភាពជាតិ
# ស្តីពី
# ការទប់ស្កាត់អំពើហិង្សាលើស្ត្រី
# ២០១៩-២០២៣

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០

រៀបចំដោយក្រសួងកិច្ចការនារី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកការលុបបំបាត់អំពើហិង្សាលើស្ត្រី ជាកម្មវិធីអាទិភាពមួយដែលគ្រប់ក្រសួងស្ថាប័ន វិស័យឯកជន និងសង្គមស៊ីវិលត្រូវចូលរួមអនុវត្ត ឱ្យម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ បង្ក្រាប និងការពារជនរងគ្រោះឱ្យបានទាន់ពេលវេលា និងប្រកប ដោយប្រសិទ្ធភាព ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

អំពើហិង្សាលើស្ត្រីគឺជាការរំលោភសិទ្ធិស្ត្រីដែលជាសិទ្ធិមនុស្សនិងបានបង្កឧបសគ្គដ៏ ចម្បងរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍជាតិ ដែលប្រការនេះគឺជាការដាក់បន្ទុក យ៉ាងធ្ងន់ធ្ងរលើសេដ្ឋកិច្ចជាតិនិងសង្គម ព្រោះរដ្ឋបានខាតបង់ថវិកាលើការចំណាយសម្រាប់ សេវាសុខភាព ការបាត់បង់ផលិតភាព ជម្រកសុវត្ថិភាពសម្រាប់ស្ត្រីរងគ្រោះនិងកូន សេវាសង្គម ដើម្បីស្តារនីតិសម្បទាស្ត្រីរងគ្រោះ សេវាច្បាប់និងសេវាគាំទ្រចាំបាច់មួយចំនួនទៀត។

ដើម្បីសម្រេចបានគោលបំណងនេះ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តយ៉ាងខ្ជាប់ខ្ជួន នូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ គោលនយោបាយនិងកម្មវិធីតាមវិស័យ ជាពិសេស ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលមានលក្ខណៈសម្បត្តិទី៣ចែងថា "គ្មាន អំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ" ព្រមទាំងបានបង្កើតយន្តការ ច្បាប់ គោលនយោបាយ និងផែនការសកម្មភាពជាតិ ដើម្បីឆ្លើយតបចំពោះអំពើហិង្សាគ្រប់ទម្រង់ លើស្ត្រី និងក្មេងស្រី និងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាជាពហុវិស័យជួយ ជនរងគ្រោះដោយអំពើហិង្សាឱ្យបានទាន់ពេលវេលា។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព៖ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ បានកំណត់ការពង្រឹងសមភាព យេនឌ័រ នៅក្នុងមុំទី៤ នៃចតុកោណទី១ ស្តីពីការអភិវឌ្ឍធនធានមនុស្ស ដោយរាជរដ្ឋាភិបាល ផ្តោតលើការពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ តាមរយៈគោលដៅ ជាយុទ្ធសាស្ត្រ៖ ទី១. ការបន្តលើកកម្ពស់តួនាទីស្ត្រីតាមរយៈការបង្កើនសមាមាត្រនិងការពង្រឹង សមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងកម្រិតនយោបាយ និង កម្រិតជំនាញ។ ទី២. ការធ្វើបច្ចុប្បន្នកម្ម និងអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ ដោយបន្ត ជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍គ្រប់ផ្នែក គ្រប់វិស័យនិង គ្រប់កម្រិត បន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំ និងបន្ត

បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រនិងពង្រឹងភាពជាដៃគូរវាងស្ថាប័នពាក់ព័ន្ធ សំដៅទប់ស្កាត់អំពើជួញដូរ និងអំពើហិង្សាលើស្ត្រី និងកុមារ។

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ គឺជាផែនការលើកទី៣ ដែលត្រូវបានអភិវឌ្ឍន៍ឡើងស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងនោះគោលដៅទី៥ ដែលចែងពី "ការសម្រេចឱ្យបានសមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រីនិងក្មេងស្រីទាំងអស់" ហើយផែនការនេះ នឹងដើរតួនាទីជាផែនទីតម្រង់ទិសសម្រាប់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយក្នុងការអនុវត្តការងារបង្ការទប់ស្កាត់ ផ្តល់កិច្ចអន្តរាគមន៍ និងកិច្ចការពារដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិខ្ពស់ឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះ។

ជាគោលការណ៍ ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនេះឱ្យទទួលបានជោគជ័យ តម្រូវឱ្យមានកិច្ចសហការ ការវិភាជន៍ធនធាន ការផ្តល់មធ្យោបាយ និងការប្តេជ្ញាចិត្តរួមពីគ្រប់ក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជននិងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងប្រជាពលរដ្ឋគ្រប់រូបផងដែរ ដើម្បីប្រែក្លាយផែនការសកម្មភាពជាតិនេះ ឱ្យទៅជាការសកម្មភាពជាក់ស្តែងនៅតាមវិស័យនីមួយៗ។ ដូច្នេះខ្ញុំមានការជឿជាក់ថាជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់និងស្មារតីនៃភាពជាម្ចាស់ក្នុងការទទួលខុសត្រូវ របស់ក្រសួងស្ថាប័ន ព្រមទាំងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់នឹងបំពេញការងារប្រកបដោយភាពទទួលខុសត្រូវខ្ពស់និងភាពជាដៃគូល្អដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រ និងសកម្មភាពចម្បងៗទាំងឡាយដែលបានកំណត់ក្នុងផែនការសកម្មភាពជាតិនេះ។

រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងមោះមុត ក្នុងការធ្វើការជាមួយដៃគូទាំងអស់ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ជាពិសេស ផ្តោតលើកិច្ចការពារស្ត្រីនិងក្មេងស្រី ដែលជាជនរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ដូចដែលបានបញ្ជាក់ក្នុងសេចក្តីថ្លែងការណ៍របស់ជាតិនៅក្នុងសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ នាទីក្រុងណៃរ៉ូប៊ី កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ថានឹងខិតខំធ្វើយ៉ាងណាឱ្យអត្រានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រស្ថិតនៅកម្រិតទាបបំផុត ដែលបច្ចុប្បន្នការងារនេះកំពុងផ្តល់ផលវិជ្ជមានគួរឱ្យគាត់សម្គាល់ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានកាត់បន្ថយជាបណ្តើរៗតាមរយៈការពង្រឹងការអនុវត្តច្បាប់និងគោលនយោបាយ។

យើងជឿជាក់ថា ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ គឺជាឯកសារគោលប្រកបដោយយុទ្ធសាស្ត្រ និងវិធីសាស្ត្រច្បាស់លាស់ក្នុងការជួយដោះស្រាយបញ្ហាគ្រប់ទម្រង់លើស្ត្រី ដើម្បីឱ្យស្ត្រីនិងក្មេងស្រីទទួលបាននូវការគោរពសិទ្ធិ រស់នៅ ក្នុងសង្គមប្រកបដោយសុវត្ថិភាព ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមយ៉ាងសកម្មនិងដោយស្មើភាពក្នុងដំណើការអភិវឌ្ឍប្រទេសជាតិ ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនាឆ្នាំ២០៣០។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការជាតិនិងអន្តរជាតិ ដែលបានផ្តល់ការគាំទ្រទាំងថវិកា និងបច្ចេកទេសក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៩-២០២៣ នេះ និងសូមអំពាវនាវដល់គ្រប់ក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជននិងសាធារណជនគ្រប់មជ្ឈដ្ឋានទាំងអស់ សូមបន្តគាំទ្រនិងរួមចំណែកឱ្យបានខ្លាំងក្លាក្នុងការអនុវត្តផែនការសកម្មភាពជាតិនេះឱ្យទទួលបានជោគជ័យ ដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជា ជាពិសេសស្ត្រីនិងក្មេងស្រី រស់នៅប្រកបដោយភាពសុខដុមរមនានិងថ្លៃថ្នូរក្នុងជីវិត។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩ -២០២៣ នឹងរួមចំណែកលើកកម្ពស់តម្លៃសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សំដៅលើកកម្ពស់សមធម៌ បរិយាបន្ន និងភាពសុខដុមរមនាក្នុងសង្គម ដែលប្រការនេះនឹងផ្តល់សុវត្ថិភាពនិងកាលានុវត្តភាពដល់ស្ត្រី និងក្មេងស្រី អាចប្រើប្រាស់សក្តានុពលរបស់ខ្លួនជាអតិបរិមា ដើម្បីចូលរួមក្នុងកិច្ចអភិវឌ្ឍជាតិ។

ថ្ងៃអង្គារ ៨កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


បញ្ជីអក្សរកាត់........................................................ ១

**១. សារបាន**........................................................ ៤

១.១. គោលនយោបាយ........................................................ ៤

១.១.១. ក្របខ័ណ្ឌជាតិ........................................................ ៤

១.១.២. ក្របខ័ណ្ឌអន្តរជាតិ........................................................ ៥

១.២. ស្ថានភាព........................................................ ៥

១.២.១. អំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាពីដៃគូស្និទ្ធស្នាល........................................................ ៨

១.២.២. ការរំលោភសេពសន្ថវៈនិងអំពើហិង្សាផ្លូវភេទ........................................................ ៨

១.២.៣. អំពើជួញដូរមនុស្ស........................................................ ៩

១.២.៤. ក្រុមស្ត្រីដែលមានហានិភ័យខ្ពស់នឹងអំពើហិង្សា........................................................ ៩

១.៣. បញ្ហាអាទិភាព........................................................ ១០

**២. យុទ្ធសាស្ត្រ**........................................................ ១០

យុទ្ធសាស្ត្រទី១. ការបង្ការ ទប់ស្កាត់........................................................ ១០

យុទ្ធសាស្ត្រទី២. កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ........................................................ ១១

យុទ្ធសាស្ត្រទី៣. ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ........................................................ ១១

យុទ្ធសាស្ត្រទី៤. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ........................................................ ១១

**៣. ផែនការសកម្មភាព**........................................................ ១១

៣.១. បរិយាយសង្ខេបអំពីវិសាលភាពផែនការ........................................................ ១១

៣.២. តារាងអនុវត្តការងារ........................................................ ១២

**៤. កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត**........................................................ ៥៣

**៥. គម្រោងចំណាយ**........................................................ ៥៤

**៦. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ**........................................................ ៥៤

**៧. សេចក្តីសន្និដ្ឋាន**........................................................ ៥៥

**សទ្ទានុក្រម**........................................................ ៥៦

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ASEAN | Association of Southeast Asia Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CEDAW | Convention on the Elimination of All Forms of Discrimination Against Women | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CWCC | Commune Committee for Women and Children | គណៈកម្មាធិការទទួលបន្ទុក កិច្ចការនារីនិងកុមារឃុំ/សង្កាត់ |
| CDHS | Cambodia Demographic and Health Survey | ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា |
| CNCW | Cambodian National Council for Women | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| CSE | Comprehensive Sexuality Education | កម្មវិធីអប់រំសុខភាពផ្លូវភេទ |
| CSO | Community Service Organization | អង្គការដែលផ្តល់សេវានៅតាមសហគមន៍ |
| DV Law | Law on Prevention of Domestic Violence and Protection of Victims | ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ |
| DMC | Department of Media and Communication | ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ |
| DV | Domestic Violence | អំពើហិង្សាក្នុងគ្រួសារ |
| DWG-GBV | District Working Group on Gender-Based Violence | ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ស្រុក |
| GBV | Gender Based Violence | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| GMAC | Garment Manufacturers Association in Cambodia | សមាគមរោងចក្រកាត់ដេរកម្ពុជា |
| IPV | Intimate Partner Violence | អំពើហិង្សាពីដៃគូស្និទ្ធស្នាល |
| LBT | Lesbian, Bisexual, Transgender | ស្ត្រីស្រឡាញ់ភេទដូចគ្នា ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរភេទ |

| | | |
|---|---|---|
| MoC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MoCFA | Ministry of Culture and Fine Arts | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| MoCR | Ministry of Cults and Religions | ក្រសួងធម្មការនិងសាសនា |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoJ | Ministry of Justice | ក្រសួងយុត្តិធម៌ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoLVT | Ministry of Labor and Vocational Training | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoINF | Ministry of Information | ក្រសួងព័ត៌មាន |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MoFAIC | Ministry of Foreign Affairs and International Cooperation | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ |
| MoPT | Ministry of Posts and Telecommunications | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| MoSVY | Ministry of Social Affairs Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MSS | Minimum Service Standards | បទដ្ឋានអប្បបរមាស្តីពីសេវា |
| NAPVAW | National Action Plan to Prevent Violence Against Women | ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី |
| NCCT | National Committee for Counter Trafficking | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| NCDD | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OSSC | One Stop Service Center | កន្លែងផ្តល់សេវាចម្រុះសម្រាប់ជនរងគ្រោះ |

| | | |
|---|---|---|
| | | ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| PWG-GBV | Provincial Working Groups on Gender-Based Violence | ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្ត |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RSA | Royal School of Administration | សាលាភូមិន្ទរដ្ឋបាល |
| RULE | Royal University of Law and Economics | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| RUPP | Royal University of Phnom Penh | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| TWGG-GBV | Technical Working Group on Gender -Gender Based Violence | ក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| UNCRC | UN Convention on the Rights of the Child | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| UNCRPD | UN Convention on the Rights of Persons with Disabilities | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ |
| UNDRIP | UN Declaration on the Rights of Indigenous People | សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច |
| UNSRC | UN Security Council Resolutions | សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ |
| UYFC | Union of Youth Federation of Cambodia | សហភាពសហព័ន្ធយុវជនកម្ពុជា |
| VAW | Violence against Women | អំពើហិង្សាលើស្ត្រី |

# ១- សារបាន

## ១.១- គោលនយោបាយ

### ១.១.១- ក្របខ័ណ្ឌជាតិ

ស្ត្រី មានតួនាទីសំខាន់ក្នុងសង្គមកម្ពុជានិងជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គមជាតិ។ ដើម្បីលើកកម្ពស់និងការពារសិទ្ធិស្ត្រី ជាពិសេសទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើស្ត្រី រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាច្រើន ដែលឯកសារទាំងនោះរួមមាន៖

ក. **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានហាមឃាត់ដាច់ខាតចំពោះការរើសអើងលើស្ត្រីភេទ ហើយក្នុងមាត្រា៤៥ ចែងថា "ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល។ ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីភេទក្នុងការងារ ត្រូវហាមឃាត់"។ មាត្រា៣៨ ចែងថា "ច្បាប់ការពារមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ" និងមាត្រា៤៦ ចែងថា "អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់..."។

ខ. **ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧** រាល់ទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រីនិងកុមារ អាចផ្តន្ទាទោសបាន នៅក្រោមក្រមព្រហ្មទណ្ឌ ហើយរបៀបនៃការផ្តន្ទាទោសត្រូវអនុត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

គ. **ក្រមរដ្ឋប្បវេណី ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦** សមាជិកគ្រួសារ ត្រូវគោរពសិទ្ធិនិង សេរីភាពគ្នាទៅវិញទៅមកនិងត្រូវទប់ស្កាត់មិនឱ្យមានអំពើហិង្សាក្នុងគ្រួសារ។

ឃ. **ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ(ឆ្នាំ២០០៥)** ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងពង្រឹងវប្បធម៌អហិង្សានិងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គម នៅព្រះរាជាណាចក្រកម្ពុជា។

ង. **ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ(ឆ្នាំ២០០៨)** ហាមឃាត់អំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទតាមរូបភាពផ្សេងៗ។

ច. **ច្បាប់ស្តីពីការងារ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ច្បាប់ពាក់ព័ន្ធដទៃទៀត ហាមឃាត់មិនឱ្យមានការបៀតបៀនផ្លូវភេទនិងឥរិយាបថមិនសមរម្យនៅកន្លែងធ្វើការ។

ឆ. **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងមុំទី៤ ចតុកោណទី១ ស្តីពីការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម** បានចែងថា "គោលដៅយុទ្ធសាស្ត្ររបស់ រាជរដ្ឋាភិបាលកម្ពុជា គឺពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាព សង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសង្គមនិងសេដ្ឋកិច្ច"។

ជ. **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា** បានបញ្ជាក់ពីសារៈសំខាន់នៃ "ការវិនិយោគលើសមភាពយេនឌ័រ រួមជាមួយការពង្រឹងភាពជាដៃគូរវាងភាគីពាក់ព័ន្ធដើម្បីទប់ស្កាត់ការជួញដូរនិងអំពើហិង្សាលើស្ត្រីនិងកុមារ"។

ឈ. **គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព(ឆ្នាំ២០១០)**។

ញ. **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** (NSDP) **២០១៩-២០២៣**។

### ១.១.២- ក្របខ័ណ្ឌអន្តរជាតិ

ក្រៅពីក្របខ័ណ្ឌគតិយុត្តជាតិ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិមួយចំនួន ដើម្បីការពារសិទ្ធិស្រ្តី ក្នុងនោះរួមមាន៖

- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW) ក្នុងឆ្នាំ១៩៩២ និងពិធីសារតាមជម្រើសក្នុងឆ្នាំ២០១០
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ(CRC) ក្នុងឆ្នាំ១៩៩២
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ(UNCRPD)
- សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច(UNDRIP)
- ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSRC) លេខ១៣២៥ លេខ ១៨២០ លេខ១៨៨៨ ដែលទាក់ទងនឹងស្រ្តី សន្តិភាព និងសន្តិសុខ(WPS)។

- គោលដៅទី៥នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលលើកឡើងអំពី "ការសម្រេចឱ្យបានសមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រីនិងក្មេងស្រីទាំងអស់" បានរំលេចអំពីចំណុចដៅដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី នៅក្នុងវិស័យសាធារណៈនិងឯកជន រួមទាំងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច។

ព្រះរាជាណាចក្រកម្ពុជា ក៏បានចូលរួមប្តេជ្ញាចិត្តនៅថ្នាក់តំបន់ ដើម្បីការពារសិទ្ធិស្ត្រី ដែលការប្តេជ្ញាចិត្តសំខាន់ៗទាំងនោះរួមមាន៖

- សេចក្តីប្រកាសអាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០០៤
- សេចក្តីប្រកាសអាស៊ានស្តីពីការប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ឆ្នាំ២០០៤
- សេចក្តីប្រកាសអាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារ ឆ្នាំ២០១៣
- ផែនការសកម្មភាពប្រចាំតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារ ឆ្នាំ២០១៧
- ការយល់ស្របរបស់អាស៊ានលើការលើកកម្ពស់និងកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ឆ្នាំ២០១៨
- អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ឆ្នាំ២០១៥។

## ១.២- ស្ថានភាព

អំពើហិង្សាលើស្ត្រី គឺជាសកម្មភាពមួយនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលធ្វើឱ្យឬអាចធ្វើឱ្យមានគ្រោះថ្នាក់ រងទុក្ខលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តចំពោះស្ត្រី ដែលសកម្មភាពទាំងនោះរួមមាន ការគំរាមកំហែង ការបង្ខិតបង្ខំ ឬការដកហូតសិទ្ធិសេរីភាព ហើយអាចកើតមាននៅទីសាធារណៈឬនៅក្នុងជីវិតឯកជន។ បុព្វហេតុចម្បងនៃអំពើហិង្សាលើស្ត្រី ត្រូវបានទទួលស្គាល់នៅទូទាំងពិភពលោកថា បណ្តាលមកពីមានវិសមភាពយេនឌ័រនិងការរើសអើង[១]។

ស្ត្រីមួយចំនួននៅប្រទេសកម្ពុជា នៅតែប្រឈមនឹងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងសេដ្ឋកិច្ច ដែលអំពើហិង្សាទាំងនោះអាចកើតមានទាំងនៅក្នុងផ្ទះ នៅកន្លែងធ្វើការ និងក្នុងសហគមន៍ ហើយគ្រប់ទម្រង់នៃអំពើហិង្សាទាំងនេះអាចកើតឡើងចំពោះស្ត្រីដោយមិនគិតអំពីកម្រិតនៃប្រាក់ចំណូល កម្រិតវប្បធម៌ និងចំណេះដឹងឡើយ។ ទម្រង់នៃអំពើហិង្សាលើស្ត្រីដែលកើតឡើងភាគច្រើននៅកម្ពុជា គឺអំពើហិង្សាក្នុងគ្រួសារ (អំពើហិង្សា ពីដៃគូស្និទ្ធស្នាល) និងអំពើហិង្សាផ្លូវភេទ[២]។

បច្ចុប្បន្ននេះ ការយល់ដឹងរបស់សង្គមកាន់តែមានការរីកចម្រើនឡើង ហើយទទួលស្គាល់ថា ក្រុមស្ត្រីដែលប្រឈមនឹងការរើសអើងនិងកត្តាវិសមភាព បានធ្វើឱ្យពួកគេកាន់តែមានភាពងាយរងគ្រោះនឹងអំពើហិង្សា។ បទដ្ឋានសង្គម ការប្រមាថមាក់ងាយ និងការរើសអើង ធ្វើឱ្យក្រុមងាយរងគ្រោះទាំងនេះ អាចកាន់តែមានហានិភ័យនៃអំពើហិង្សានិងបញ្ហាប្រឈមនានាក្នុងការទទួលបានកិច្ចការពារនិងសេវាផ្សេងៗ។

រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនតាមរយៈកិច្ចខិតខំប្រឹងប្រែងដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី ដែលសមិទ្ធផលទាំងនោះត្រូវបានរំលេចក្នុងឯកសារ ស្តីពីការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤-២០១៨ រួមមាន៖

- បានសម្រេចនិងកំពុងអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី
- បានដាក់ឱ្យប្រើប្រាស់សាកល្បងនូវដីកាឃុំស្តីពីការគ្រប់គ្រងគ្រឿងស្រវឹង
- បានដាក់ឱ្យប្រើប្រាស់យុទ្ធសាស្ត្រស្តីពី "ការចិញ្ចឹមកូនបែបវិជ្ជមាន"
- បានសម្រេចនិងកំពុងអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- បានសម្រេចនិងកំពុងអនុវត្តបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីនិងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- បានសម្រេចនិងកំពុងអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រីនិងកុមារនៅកម្ពុជា
- បានសម្រេចនិងកំពុងអនុវត្តសេចក្តីណែនាំស្តីពីការប្រមូលទិន្នន័យនៃការផ្តល់សេវានិងការបញ្ជូនលើករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- បានបញ្ចប់ការរៀបចំនូវឯកសារណែនាំស្តីពីការគ្មានការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការនិងការបង្ការទប់ស្កាត់ជាកញ្ចប់នឹងអនុវត្តនៅតាមរោងចក្រកាត់ដេរមួយចំនួន
- បានសម្រេចនិងកំពុងអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រីនិងកុមារ និងសៀវភៅស្តីពី **"ការគ្រប់គ្រងនិងថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាលនិងអំពើហិង្សាផ្លូវភេទ"**
- ត្រឹមចុងឆ្នាំ២០១៨ កន្លែងផ្តល់សេវាសុខភាពចំនួន១០១ បានទទួលការបណ្តុះបណ្តាលអំពីការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីសម្រាប់វិស័យសុខាភិបាល ផ្អែកតាមគោលការណ៍ណែនាំជាតិ ព្រមទាំងបានផ្តល់សេវានានាដល់ជនរងគ្រោះដោយអំពើហិង្សា[៣]
- បានផ្តួចផ្តើមនូវកិច្ចពិភាក្សាដើម្បីរៀបចំផែនការសម្រាប់ការពិនិត្យឡើងវិញ លើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥
- បានរៀបចំកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធរបស់ក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយបានរៀបចំកិច្ចប្រជុំសម្របសម្រួលជាទៀងទាត់និងផ្តួចផ្តើមអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ រួមគ្នារវាងក្រសួងសំខាន់ៗចំនួនប្រាំ រួមមានក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានបង្កើតក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅថ្នាក់ក្រោមជាតិ នៅក្នុងខេត្តចំនួន៨(ព្រះវិហារ ស្ទឹងត្រែង កំពង់ចាម ត្បូងឃ្មុំ កំពង់ស្ពឺ កំពង់ធំ សៀមរាប និងព្រះសីហនុ)

ដើម្បីបង្កើនកិច្ចសហការនិងការសម្របសម្រួលក្នុងការផ្តល់សេវាដល់ជនរងគ្រោះ រវាងអ្នកផ្តល់សេវាសំខាន់ៗ

- កំពុងរៀបចំសាកល្បងបង្កើតកន្លែងផ្តល់សេវាចម្រុះ (OSSC) នៅមន្ទីរពេទ្យខេត្តចំនួន២ គឺកំពង់ចាម និងស្ទឹងត្រែង
- បានអនុវត្តសាកល្បងនូវគម្រោងស្តីពី "អភិវឌ្ឍន៍ទំនាក់ទំនងប្រកបដោយផាសុកភាពនិងភាពសប្បាយរីករាយ" ដោយផ្តោតលើមនុស្សវ័យក្មេង សម្រាប់ការបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រីជាពិសេសក្មេងស្រី
- បានដាក់បញ្ចូលមេរៀនទាក់ទងនឹងការផ្លាស់ប្តូរបទដ្ឋានសង្គមទៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីបទដ្ឋានអប្បបរមាក្នុងការផ្តល់សេវាសម្រាប់មន្ត្រីផ្តល់សេវាសាធារណៈនិងអង្គការពាក់ព័ន្ធ
- បានរៀបចំយុទ្ធនាការ "ហេតុអ្វីត្រូវបញ្ឈប់?" ដែលផ្តោតសំខាន់លើការបៀតបៀនផ្លូវភេទ
- បានធ្វើការផ្សព្វផ្សាយតាមរយៈសកម្មភាពផ្សេងៗ ដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ជាពិសេសក្នុងយុទ្ធនាការ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី
- បណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារីនៅគ្រប់រាជធានី ខេត្តទាំងអស់ ដោយប្រើប្រាស់ឯកសារគោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី
- បានអនុវត្តសាកល្បងការប្រមូលទិន្នន័យទាក់ទងនឹងការផ្តល់សេវានិងការបញ្ជូន
- បានបង្កើនថវិកាដើម្បីឆ្លើយតបនឹងតម្រូវការបន្ទាន់របស់ជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី
- បានធ្វើការវិភាគលើកទី២ លើសំណុំទិន្នន័យដែលមានស្រាប់ក្នុងប្រព័ន្ធផ្សព្វផ្សាយ ការប្រើប្រាស់គ្រឿងស្រវឹង ការបំពារបំពានលើកុមារ និងការអប់រំ ដើម្បីកំណត់វិស័យសំខាន់ៗសម្រាប់កិច្ចអន្តរាគមន៍។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដ៏ត្រចះត្រចង់នេះ ក៏នៅមានបញ្ហាប្រឈមដែលនៅសេសសល់និងបញ្ហាប្រឈមថ្មីៗមួយចំនួន ដូចជាកង្វះធនធានក្នុងការធ្វើការងារបង្ការទប់ស្កាត់និងកិច្ចសម្របសម្រួលក្នុងការផ្តល់សេវានៅមានកម្រិតនៅឡើយ ក្នុងនោះកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការ ទប់ស្កាត់ត្រូវបានអនុវត្តដោយផ្អែកលើគម្រោងកម្មវិធីនិងមិនទាន់បានទូលំទូលាយ។ បទដ្ឋានអប្បបរមាពាក់ព័ន្ធនឹងការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាសេវាសុខភាព ការសម្រុះសម្រួល ការបញ្ជូន និងសេវាផ្សេងៗទៀតត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងមួយចំនួនទៀតកំពុងអភិវឌ្ឍ ដែលបទដ្ឋានទាំងនេះគឺជាជំហានដ៏សំខាន់ឆ្ពោះទៅការបង្កើនគុណភាពនៃសេវា ប៉ុន្តែការបណ្តុះបណ្តាលដើម្បីកសាងសមត្ថភាពសម្រាប់ការអនុវត្ត នៅមិនទាន់បានគ្រប់ជ្រុងជ្រោយ ដោយអនុវត្តសាកល្បងនៅតាមបណ្តាខេត្តមួយចំនួនតូចប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត កន្លែងផ្តល់សេវាមួយចំនួនស្ថិតនៅឆ្ងាយពីជនរងគ្រោះ ធ្វើឱ្យពួកគាត់ខ្វះលទ្ធភាពក្នុងការទទួលបានសេវា ឬត្រូវចំណាយខ្ពស់សម្រាប់ការធ្វើដំណើរ។ ទន្ទឹមនឹងនេះដែរ ស្ត្រីដែលអាចមានលទ្ធភាពក្នុងការស្វែងរកយុត្តិធម៌តាមប្រព័ន្ធតុលាការ នៅមិនទាន់មានចំនួនច្រើននៅឡើយ ហើយការសម្រុះសម្រួលវិវាទក្រៅប្រព័ន្ធតុលាការក៏នៅកើតមានដែលប្រការនេះមិនទាន់អនុលោមបានតាមគោលការណ៍ដែលផ្តោតការយកចិត្តទុកដាក់ទៅលើជនរងគ្រោះនៅឡើយ។ បើទោះបីជាការសម្រុះសម្រួលវិវាទក្រៅប្រព័ន្ធតុលាការ មានប្រយោជន៍ដល់ជនរងគ្រោះក៏ដោយ ដំណោះស្រាយរបស់យើងបានផ្អែកលើមូលដ្ឋានច្បាប់ ដោយភ្ជាប់ទៅនឹងប្រភេទនិងកម្រិតនៃបទល្មើស។ ទន្ទឹមនេះដែរ ការស្វែងរកយុត្តិធម៌តាមប្រព័ន្ធតុលាការនៅជួបការលំបាក ព្រោះអំពើហិង្សាលើស្ត្រីនៅតែកើតមាន ហើយទីតាំងកើតហេតុច្រើនមាននៅតំបន់ជនបទ។ ម្យ៉ាងវិញទៀត ចំនួនមេធាវីនៅមិនទាន់គ្រប់គ្រាន់សម្រាប់

ការឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះនៅឡើយ ប៉ុន្តែដំណោះស្រាយយ៉ាងល្អចំពោះមុខដែលបានធ្វើ គឺកិច្ចសហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមមេធាវីស្ម័គ្រចិត្តសម្ដេចតេជោសែន។ កិច្ចសហការនេះត្រូវបានលើកឡើងសម្រាប់ដំណោះស្រាយជាក់លាក់ដាក់នៅក្នុងផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដោយតម្រូវឱ្យភាគីពាក់ព័ន្ធចូលរួមអនុវត្តជាមួយគ្នា។

ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ការសិក្សាស្រាវជ្រាវសំខាន់ៗទាក់ទងនឹងអំពើហិង្សាលើស្ត្រី ត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងនោះមានការសិក្សាថ្មីចំនួនពីរ (ការអង្កេតស្ដីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា(CDHS) ឆ្នាំ២០១៤ និងការសិក្សាថ្នាក់ជាតិអំពីសុខភាពរបស់ស្ត្រីនិងបទពិសោធជីវិត ឆ្នាំ២០១៥) ដែលការសិក្សាទាំងនេះ បានផ្ដល់នូវទិន្នន័យកម្រិតថ្នាក់ជាតិដើម្បីបង្កើនការយល់ដឹងអំពីប្រេវ៉ាឡង់នៃអំពើហិង្សាពីដៃគូស្និទ្ធស្នាលនិងអំពើហិង្សាផ្លូវភេទ។ នៅក្នុងឆ្នាំ២០១៦ ការសិក្សាស្ដីពី បទពិសោធរបស់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនិងទម្រង់ផ្សេងៗទៀតនៃអំពើហិង្សា ត្រូវបានធ្វើឡើងតាមរយៈការវិភាគស៊ីជម្រៅទៅលើទិន្នន័យនៃការសិក្សាទាំងពីរខាងលើ ហើយលទ្ធផលដែលទទួលបានជាមួយនឹងលទ្ធផលនៃការសិក្សាផ្សេងទៀត បានផ្ដល់នូវការយល់ដឹងកាន់តែប្រសើរឡើងអំពីស្ថានភាពបច្ចុប្បន្ននៃអំពើហិង្សាលើស្ត្រីនៅកម្ពុជា។

### ១.២.១. អំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាពីដៃគូស្និទ្ធស្នាល

អំពើហិង្សាលើស្ត្រីដែលកើតមានជាញឹកញាប់នោះ គឺអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាពីដៃគូស្និទ្ធស្នាល ហើយបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងផ្ដោតការយកចិត្តទុកដាក់ក្នុងការដោះស្រាយ។ ការសិក្សាបានបង្ហាញថា៖

ក. ស្ត្រី១នាក់ក្នុងចំណោម៥នាក់ដែលមានអាយុពី១៥-៤៩ឆ្នាំ បានរាយការណ៍ថា ធ្លាប់រងគ្រោះដោយអំពើហិង្សាលើរាងកាយយ៉ាងហោចណាស់ម្ដងចាប់តាំងពីគាត់មានអាយុ១៥ឆ្នាំ ហើយ៩% បានទទួលរងអំពើហិង្សាលើរាងកាយក្នុងរយៈពេល១២ខែចុងក្រោយមុនការធ្វើអង្កេត ស្ត្រីធ្លាប់រៀបការដែលមានអាយុពី១៥-៤៩ឆ្នាំចំនួន១៨% បានរាយការណ៍ថា ធ្លាប់ទទួលរងគ្រោះដោយអំពើហិង្សាលើរាងកាយឬផ្លូវភេទពីប្ដី[៤]។

ខ. ក្នុងចំណោមស្ត្រីរងគ្រោះ៥នាក់ មានស្ត្រីប្រហែល២នាក់បានសុំជំនួយដើម្បីបញ្ឈប់អំពើហិង្សាដែលពួកគេបានរងគ្រោះ ប៉ុន្តែមានតែ២៤% ប៉ុណ្ណោះដែលបានស្វែងរកជំនួយពីសេវាផ្លូវការ[៥]។

### ១.២.២. ការរំលោភសេពសន្ថវៈនិងអំពើហិង្សាផ្លូវភេទ

ក. ស្ត្រីដែលមានអាយុពី១៥-៤៩ឆ្នាំ ចំនួន៦% បានរាយការណ៍ថា ធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទយ៉ាងហោចណាស់ម្ដងក្នុងមួយជីវិត[៦]។

ខ. ស្ត្រី៥% បានរាយការណ៍ថា ពួកគេធ្លាប់ទទួលរងការបៀតបៀនផ្លូវភេទយ៉ាងហោចណាស់ម្ដងក្នុងមួយជីវិត[៦]។

គ. ក្មេងស្រី៤% បានរាយការណ៍ថា ធ្លាប់ទទួលរងការបំពានផ្លូវភេទយ៉ាងហោចណាស់ម្ដង មុនអាយុ១៨ឆ្នាំ[៧]។

ឃ. ករណីនៃការរំលោភបំពានខាងផ្លូវភេទដែលប្រព្រឹត្តដោយជនប្រព្រឹត្តលើសពី១នាក់ ក៏កើតមានផងដែរ ក្នុងនោះស្ត្រី១នាក់ក្នុងចំណោមស្ត្រី១០នាក់និងបុរស១នាក់ក្នុងចំណោម៤នាក់ ដែលមានអាយុពី១៨ឆ្នាំដល់២៤ឆ្នាំ បានរាយការណ៍ថា ទទួលរងនូវការរំលោភបំពានខាងផ្លូវភេទលើកទីមួយ នៅពេលដែលពួកគេជាអនីតិជន ដែលប្រព្រឹត្តដោយជនប្រព្រឹត្តលើសពី១នាក់។ របាយការណ៍ក៏បានឱ្យដឹងថា ក្មេងស្រី១នាក់ក្នុងចំណោម៨នាក់និងក្មេងប្រុស១នាក់ក្នុងចំណោម៦នាក់ ដែលមានអាយុពី១៣ឆ្នាំ ដល់១៧ឆ្នាំ បានរាយការណ៍ថា ធ្លាប់ទទួលរងការរំលោភបំពានខាងផ្លូវភេទលើកទីមួយ ដែលប្រព្រឹត្តដោយជនប្រព្រឹត្តលើសពី១នាក់[៨]។

### ១.២.៣- អំពើជួញដូរមនុស្ស

អំពើជួញដូរមនុស្ស គឺជាការរំលោភបំពានសិទ្ធិមនុស្សនិងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវិតស្ត្រី ប៉ុន្តែបញ្ហានេះមិនត្រូវបានរំលេចនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ នោះទេ អាស្រ័យដោយប្រទេសកម្ពុជាមានផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៩-២០២៣ ដាច់ដោយឡែក។ វិស័យអាទិភាពនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ និងផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៩-២០២៣ គឺបំពេញឱ្យគ្នាទៅវិញទៅមក។

### ១.២.៤- ក្រុមស្ត្រីដែលមានហានិភ័យខ្ពស់នឹងអំពើហិង្សា

ស្ត្រីស្ថិតនៅក្នុងក្រុមងាយរងគ្រោះ មានហានិភ័យខ្ពស់ពីការរំលោភបំពានសិទ្ធិ រួមទាំងអំពើហិង្សា ហើយមួយចំនួននៅមិនទាន់ទទួលបានកិច្ចការពារគ្រប់គ្រាន់នៅឡើយ ដែលបញ្ហានេះអាចបណ្តាលមកពីការងាររបស់ពួកគេ ហេដ្ឋារចនាសម្ព័ន្ធ សហគមន៍ កិច្ចអន្តរាគមន៍ ការញៀនថ្នាំ សុខភាព ស្ថានភាពសេដ្ឋកិច្ច អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ សាសនា ជាតិសាសន៍ និងការជាប់ឃុំឃាំងជាដើម។ នៅប្រទេសកម្ពុជា ក្រុមស្ត្រីដែលមានហានិភ័យខ្ពស់នឹងភាពរងគ្រោះ រួមមានស្ត្រីមានពិការភាព ស្ត្រីមានផ្ទុកមេរោគអេដស៍ ស្ត្រីស្រឡាញ់ភេទដូចគ្នា ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរភេទ (LBT) ស្ត្រីពលករទេសន្តរប្រវេសន៍ ស្ត្រីបម្រើការងារនៅកន្លែងកម្សាន្ត ស្ត្រីប្រកបរបរផ្លូវភេទ កម្មការិនីរោងចក្រកាត់ដេរនិងកម្មការិនីដទៃទៀត ស្ត្រីញៀនថ្នាំឬស្ត្រីដែលដៃគូរបស់គេញៀនថ្នាំ ស្ត្រីជាប់ពន្ធនាគារ ស្ត្រីចាស់ជរា ស្ត្រីជនជាតិដើមភាគតិច ស្ត្រីជនជាតិភាគតិច ឬស្ត្រីក្នុងក្រុមសាសនាដែលមានអ្នកគោរពប្រតិបត្តិភាគតិច។ របាយការណ៍ស្តីពី គ្រោះមហន្តរាយថ្នាក់ជាតិជាសាកល យល់ស្របជាទូទៅថា នៅពេលគ្រោះមហន្តរាយកើតឡើង ស្ត្រីមានកម្រិតប្រឈមខ្ពស់នឹងអំពើហិង្សាផ្លូវភេទ ការកេងប្រវ័ញ្ច ការរំលោភបំពាន អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ។ ស្ត្រីដែលធ្លាប់ទទួលរងគ្រោះ ដោយអំពើហិង្សា មានភាពប្រឈមនឹងអំពើហិង្សាកាន់តែខ្លាំងជាងមុន នៅពេលដែលមានគ្រោះមហន្តរាយកើតឡើង ដោយហេតុថាពួកគេត្រូវបានកាត់ផ្តាច់ពីប្រព័ន្ធជំនួយនិងប្រព័ន្ធការពារ។ ស្ត្រីមួយចំនួនមានតម្រូវការជាក់លាក់ដែលតម្រូវឱ្យដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបផ្សេងគ្នានិងកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការ ទប់ស្កាត់ ជាពិសេស។

ក. ស្ត្រីដែលរស់នៅតាមទីជនបទ មានអត្រារងគ្រោះដោយអំពើហិង្សាលើរាងកាយខ្ពស់ជាងស្ត្រីនៅទីក្រុង[៩]។

ខ. តួលេខស្ត្រីដែលមានពិការភាពដែលទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល មានអត្រាប្រហាក់ប្រហែលគ្នាជាមួយស្ត្រីទូទៅដែរ ប៉ុន្តែឥរិយាបថគ្រប់គ្រងពីដៃគូមានអត្រាខ្ពស់ជាង ហើយអ្វីគួរឱ្យកត់សម្គាល់នោះ គឺគ្រប់ប្រភេទនៃអំពើហិង្សា (ខាងផ្លូវចិត្ត ផ្លូវកាយ ផ្នែកជីវភាពសេដ្ឋកិច្ច និងផ្លូវភេទ) ពីសមាជិកគ្រួសារមានកម្រិតខ្ពស់ បើប្រៀបធៀបទៅនឹងស្ត្រីដទៃទៀត។ ឧបសគ្គក្នុងការរាយការណ៍អំពីការរងគ្រោះដោយអំពើហិង្សានិងលទ្ធភាពទទួលបានសេវា ក៏មានភាពលំបាកដោយសារស្ត្រីដែលមានពិការភាពមួយចំនួន ខ្វះស្វ័យភាពហិរញ្ញវត្ថុនិងមានភាពអង់អាចតិចជាងស្ត្រីដែលមិនមានពិការភាព[១០]។

គ. ការសិក្សាបែបគុណភាពអំពីស្ត្រីនៅក្នុងសហគមន៍ជនជាតិដើមភាគតិច បានរកឃើញថា ស្ត្រីជនជាតិដើមភាគតិចក៏បានរាយការណ៍អំពីភាពរងគ្រោះពីអំពើហិង្សាគ្រប់ប្រភេទនិងរាយការណ៍អំពីបញ្ហាប្រឈមក្នុងការទទួលសេវាយុត្តិធម៌ ជម្រកសុវត្ថិភាព សេវាប្រឹក្សាផ្លូវចិត្ត ការគាំទ្រផ្នែកច្បាប់ និងសេវាផ្សេងៗទៀត[១១]។

ឃ. អំពីស្ត្រីដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ការសិក្សាមួយបានរកឃើញថា ស្ត្រីមួយចំនួនធ្លាប់រងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំផងដែរហើយបានផ្តល់នូវផលវិបាកជាច្រើនដល់ស្ត្រីដែលនៅរស់រានមានជីវិតទាំងនោះ ពាក់ព័ន្ធទៅនឹងអត្តសញ្ញាណ គុណតម្លៃរបស់ខ្លួន ស្ថានភាពសង្គម និងសេដ្ឋកិច្ចគ្រួសារ។ របួសផ្លូវចិត្តបានចាក់ជ្រៅទៅក្នុងចិត្តនិងបានបន្តទៅកាន់មនុស្សជំនាន់ក្រោយផងដែរ ដែលជាផលវិបាករយៈពេលវែង ស្របពេលដែលការផ្តល់កិច្ចគាំទ្រនៅមានកម្រិតនៅឡើយសម្រាប់ការព្យាបាលផ្លូវចិត្តដែលពួកគាត់បានជួបប្រទះ។

## ១.៣. បញ្ហាអាទិភាព

ការសិក្សាអំពីស្ថានភាពនៃអំពើហិង្សាលើស្ត្រីនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថា ស្ត្រីមួយចំនួននៅតែប្រឈមនឹងអំពើហិង្សានៅឡើយ។ ប្រភេទនៃអំពើហិង្សាបានកើតមានជាយូរមកហើយនៅក្នុងសង្គមកម្ពុជារួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកជីវភាពសេដ្ឋកិច្ច ហើយជាងនេះទៀត បញ្ហាប្រឈមថ្មីដែលកំពុងកើតឡើង គឺអំពើហិង្សាលើស្ត្រីដែលស្ថិតក្នុងក្រុមងាយរងគ្រោះ។

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ បានកំណត់អាទិភាពសំខាន់ៗ ដើម្បីបង្ការ ទប់ស្កាត់ស្របតាមស្ថានភាពនៃទម្រង់អំពើហិង្សានីមួយៗនិងផ្អែកលើបទប្បញ្ញត្តិដែលមាននាពេលបច្ចុប្បន្ន។

បញ្ហាសំខាន់ៗចំនួន៤ ដែលត្រូវបានកំណត់ជាបញ្ហាអាទិភាព រួមមាន៖

- អំពើហិង្សាក្នុងគ្រួសារ
- អំពើហិង្សាពីដៃគូស្និទ្ធស្នាល
- ការរំលោភសេពសន្ថវៈនិងអំពើហិង្សាផ្លូវភេទ
- អំពើហិង្សាលើស្ត្រីដែលកើតមានក្នុងក្រុមស្ត្រីដែលងាយរងគ្រោះ។

# ២. យុទ្ធសាស្ត្រ

គោលដៅរួមនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ គឺដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រីរួមទាំងក្រុមដែលមានហានិភ័យខ្ពស់ តាមរយៈការបង្កើនកិច្ចអន្តរាគមន៍បង្ការទប់ស្កាត់ ការបង្កើនការឆ្លើយតប ការបង្កើនការទទួលបានសេវាប្រកបដោយគុណភាព និងការសម្របសម្រួលពហុវិស័យនិងកិច្ចសហការ។ យុទ្ធសាស្ត្រសំខាន់ៗចំនួន៤ ត្រូវបានកំណត់ថា ជាយុទ្ធសាស្ត្រចម្បងដែលត្រូវផ្តោតការយកចិត្តទុកដាក់រួមមាន៖

ទី១. ការបង្ការ ទប់ស្កាត់

ទី២. កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ

ទី៣. ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ

ទី៤. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ។

ដោយផ្អែកលើមូលដ្ឋានទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានណែនាំពីយុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗដូចខាងក្រោម៖

### យុទ្ធសាស្ត្រទី១. ការបង្ការ ទប់ស្កាត់

ក. ពង្រឹងការសម្របសម្រួលនិងកិច្ចសហការឱ្យមានភាពប្រសើរឡើងនៅគ្រប់កម្រិត រវាងក្រសួង ស្ថាប័នដៃគូអភិវឌ្ឍ អ្នកផ្តល់សេវា សង្គមស៊ីវិល វិស័យឯកជន ក្នុងកិច្ចអន្តរាគមន៍បង្ការ ទប់ស្កាត់។

ខ. អភិវឌ្ឍចំណេះដឹងនិងជំនាញដល់មនុស្សវ័យជំទង់និងយុវជន ក្នុងការលើកកម្ពស់និងកសាងនូវទំនាក់ទំនងប្រកបដោយសមធម៌យេនឌ័រនិងអហិង្សា ដើម្បីផ្លាស់ប្តូរឥរិយាបថ អាកប្បកិរិយា និងការអនុវត្តដោយគោរពសិទ្ធិមនុស្ស។

គ. បង្កើនចំណេះដឹង ការយល់ដឹង និងជំនាញទាក់ទងនឹងការចិញ្ចឹមកូនបែបវិជ្ជមាន នៅក្នុងចំណោមឪពុកម្តាយ ដើម្បីកសាងគ្រួសារនិងបរិយាកាសប្រកបដោយសុវត្ថិភាព សមធម៌យេនឌ័រ និងអហិង្សា។

ឃ. លើកកម្ពស់បរិយាកាសកន្លែងធ្វើការនិងសហគមន៍ឱ្យមានសុវត្ថិភាព គ្មានការបៀតបៀនគ្រប់រូបភាព លើកកម្ពស់ផ្នត់គំនិតសង្គម រូបភាព និងសារអប់រំ ប្រកបដោយសមធម៌យេនឌ័រ ភាពអហិង្សា ព្រមទាំងសមត្ថភាពនៃប្រព័ន្ធផ្សព្វផ្សាយក្នុងការយកចិត្តទុកដាក់លើការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

ង. បង្កើនការលើកកម្ពស់សមភាពយេនឌ័រ បទដ្ឋានសង្គមបែបអហិង្សា សារអប់រំ និងសមត្ថភាពរបស់ប្រព័ន្ធផ្សព្វផ្សាយ រួមទាំងបណ្តាញផ្សព្វផ្សាយសង្គមក្នុងការយកចិត្តទុកដាក់ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

**យុទ្ធសាស្ត្រទី២- កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ**

ក. បង្កើនការសម្របសម្រួលនិងទំនាក់ទំនងរវាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសង្គមស៊ីវិល។

ខ. បង្កើនការឆ្លើយតបជាប្រព័ន្ធលើករណីអំពើហិង្សាលើស្ត្រីសម្រាប់ប្រព័ន្ធសុខាភិបាល។

គ. បង្កើនលទ្ធភាពសម្រាប់ស្ត្រីគ្រប់រូបដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងការទទួលបានយុត្តិធម៌។

ឃ. បង្កើនលទ្ធភាពសម្រាប់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សា ដើម្បីឱ្យគេទទួលបានសេវាសង្គមដែលមានការសម្របសម្រួលប្រកបដោយគុណភាពនិងទាន់ពេលវេលា។

**យុទ្ធសាស្ត្រទី៣- ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ**

ក. ក្របខ័ណ្ឌគតិយុត្តនៅកម្ពុជាក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី ត្រូវបានពង្រឹង។

ខ. ក្របខ័ណ្ឌគោលនយោបាយដែលត្រូវបានកែលម្អនិងសម្របសម្រួលបានយ៉ាងល្អ ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីប្រកបដោយប្រសិទ្ធភាព។

**យុទ្ធសាស្ត្រទី៤- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ**

ការបង្កើតក្របខ័ណ្ឌពិនិត្យតាមដាននិងការវាយតម្លៃ និងប្រព័ន្ធប្រមូលនិងតាមដានទិន្នន័យគ្រប់ជ្រុងជ្រោយសម្រាប់អនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដែលបញ្ចូលទិន្នន័យទទួលបានពីការសិក្សាស្តីពីអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រីនិងការស្រាវជ្រាវផ្សេងៗ។

# ៣- ផែនការសកម្មភាព

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ គឺផ្អែកលើចក្ខុវិស័យរបស់ផែនការយុទ្ធសាស្ត្រនារីរតនៈ ដែលលើកឡើងថា "ពលរដ្ឋកម្ពុជាទាំងពីរភេទមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ហើយស្ត្រីគួរទទួលបានសុវត្ថិភាពផ្ទាល់ខ្លួន។ ដូច្នេះពួកគេអាចចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពសង្គម និងការសម្រេចចិត្តជាសាធារណៈលើមូលដ្ឋានស្មើភាពគ្នាជាមួយបុរសនិងក្មេងប្រុស ព្រមទាំងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ច ដើម្បីធានានូវស្វ័យភាពនិងសុខុមាលភាពរបស់គ្រួសារនិងសហគមន៍។

## ៣.១- បរិយាយសង្ខេបអំពីវិសាលភាពផែនការ

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ គ្របដណ្តប់លើ៖

- គ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ដៃគូអភិវឌ្ឍ
- សង្គមស៊ីវិល
- អង្គការផ្អែកលើជំនឿ សាសនា
- ជនរងគ្រោះ
- ក្រុមងាយរងគ្រោះ
- សាធារណជនទូទៅ។

## ៣.២. តារាងអនុវត្តការងារ

អភិក្រមសម្រាប់ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី គឺផ្តល់នូវមូលដ្ឋានច្បាស់លាស់សម្រាប់កិច្ចអន្តរាគមន៍ តាមរយៈការសម្របសម្រួលនិងកិច្ចសហការ ដើម្បីបង្កើនសមត្ថភាពនិងពង្រីកកិច្ចខិតខំប្រឹងប្រែង ក្នុងគោលបំណងកាត់បន្ថយនិងបង្កើនការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី ដើម្បីផ្តល់កិច្ចការពារដល់ជនរងគ្រោះនិងកូនរបស់ពួកគេ ឱ្យមានប្រសិទ្ធភាព គុណភាព និងបានទាន់ពេលវេលា។

ការសម្របសម្រួលពហុវិស័យពីដៃគូពាក់ព័ន្ធសំខាន់ៗដែលអនុវត្តការងារទាក់ទងនឹងអំពើហិង្សាលើស្ត្រីអាចបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់កិច្ចការពារដល់ជនរងគ្រោះនិងបង្កើនឱកាសក្នុងការនាំយកជនប្រព្រឹត្តល្មើសឱ្យមកទទួលខុសត្រូវចំពោះមុខច្បាប់ និងធ្វើឱ្យការបង្ការទប់ស្កាត់កាន់តែទទួលបានលទ្ធផលល្អ។ ដំណើរការនៃការសម្របសម្រួលនិងកិច្ចសហការសម្រាប់ថ្នាក់ជាតិ ដឹកនាំដោយក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសម្រាប់ថ្នាក់ក្រោមជាតិ ដឹកនាំដោយក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលការងារនេះត្រូវបានចាប់ផ្តើមដំណើរការដូចមានលើកឡើងនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ ។

ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពជាច្រើន គឺអាស្រ័យទៅលើកិច្ចសហការនិងកិច្ចសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធដទៃទៀត ដូច្នេះគណនេយ្យភាពនិងការទទួលខុសត្រូវច្បាស់លាស់របស់អ្នកពាក់ព័ន្ធ ពិតជាមានសារៈសំខាន់ណាស់។ កិច្ចសហការនិងការសម្របសម្រួលត្រូវតែធ្វើឡើងនៅគ្រប់កម្រិត ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន (ដូចជា សាសនា សេដ្ឋកិច្ច សុខាភិបាល យុត្តិធម៌ សេវាសង្គម ប្រព័ន្ធផ្សព្វផ្សាយ អប់រំជាដើម) និងជាលក្ខណៈបុគ្គល (ជនរងគ្រោះ អ្នកធ្វើការតស៊ូមតិ និងអ្នកដឹកនាំនៅក្នុងមូលដ្ឋាន) ហើយការឆ្លើយតបដែលមានការសម្របសម្រួល មានឥទ្ធិពលក្នុងការបង្កើតឱ្យមានសមធម៌យេនឌ័រនិងការផ្លាស់ប្តូរជាវិជ្ជមានផ្សេងទៀតដែលចាំបាច់ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី។ សូចនាករជាក់លាក់មិនត្រូវបានរំលេចក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ នេះទេ ដោយសូចនាករជាក់លាក់ទាំងនេះនឹងដាក់នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗក្នុងការអនុវត្តផែនការជាតិនេះ។

**គោលបំណងរួម : *អំពើហិង្សាលើស្ត្រីគ្រប់រូបភាព ត្រូវបានកាត់បន្ថយតាមរយៈការបង្កើនកិច្ចអន្តរាគមន៍បង្ការ ទប់ស្កាត់ ការបង្កើនការឆ្លើយតបកាន់តែប្រសើរ ការបង្កើនលទ្ធភាពទទួលបានសេវាប្រកបដោយគុណភាពនិងកិច្ចសហការ និងការសម្របសម្រួលជាពហុវិស័យ។***

**សូចនាករគោលបំណងរួមទី១ :** អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាពីដៃគូស្និទ្ធស្នាល (អំពើហិង្សាក្នុងគ្រួសារ) មានការធ្លាក់ចុះ [ប្រភព ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា (CDHS)] នឹងដាក់បញ្ចូល វិធីសាស្ត្រ នៃការសិក្សាស្រាវជ្រាវស្តីពីសុខភាពស្ត្រី និងបទពិសោធក្នុងCDHS

**សូចនាករគោលបំណងរួមទី២ :** ចំនួនប្រជាជនកម្ពុជាកាន់តែច្រើនឡើង មិនពេញចិត្តចំពោះអំពើហិង្សាលើស្ត្រី (ប្រភព : ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា)

**៣.២.១. យុទ្ធសាស្ត្រទី១ : ការបង្ការ ទប់ស្កាត់**

**គោលបំណង : ដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី តាមរយៈយុទ្ធសាស្ត្របង្ការទប់ស្កាត់បឋម ដែលមានការសម្របសម្រួលពហុវិស័យជាមួយ ក្រសួង និងស្ថាប័នដែលផ្តោត ទៅលើអ្នកពាក់ព័ន្ធសំខាន់ៗ និងនៅទីកន្លែងផ្សេងៗ ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរជាវិជ្ជមាន។**

**៣.២.១.១. ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ**

លទ្ធផលទី១ : ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ មានភាពប្រសើរឡើងនៅគ្រប់កម្រិតរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អ្នកផ្តល់សេវា សង្គមស៊ីវិល វិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយ គ្រឹះស្ថានសិក្សា អ្នកដឹកនាំសាសនា សមាគម សហជីព និងសហគមន៍ក្នុងកិច្ចអន្តរាគមន៍បង្ការ ទប់ស្កាត់។

សូចនាករលទ្ធផល :

១ក. យុទ្ធសាស្ត្របង្ការ ទប់ស្កាត់បឋមជាពហុវិស័យគ្រប់ជ្រុងជ្រោយមួយត្រូវបានរៀបចំនិងអនុវត្ត។

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេលមធ្យម ៣-៥ ឆ្នាំ | រយៈពេលវែងលើសពី ៥ ឆ្នាំ | |
| ១. រៀបចំសារអប់រំ បង្ការ ទប់ស្កាត់បឋម ជារួម និង/ឬយុទ្ធសាស្ត្រប្រាស្រ័យ ទាក់ទង ដើម្បីគាំទ្រដល់ការអនុវត្តអភិក្រមសម្របសម្រួលសម្រាប់បង្ការទប់ស្កាត់បឋមដែលមានការសម្របសម្រួលនិងស្របទៅ | ក. ចំនួនសារអប់រំ បង្ការ ទប់ស្កាត់បឋមជារួម ដែលត្រូវបានរៀបចំនិងអនុវត្ត<br>ខ. ចំនួនយុទ្ធសាស្ត្របង្ការ ទប់ស្កាត់បឋមដែលត្រូវបាន | - សារ និង/ឬយុទ្ធសាស្ត្របង្ការ ទប់ស្កាត់បឋមរួមមានការអប់រំដល់យុវជន គ្រួសារ និងកូនៗ សហគមន៍និងកន្លែងធ្វើការ ត្រូវបានបង្កើតឡើងនិងផ្សព្វផ្សាយ ។ | • ក្រសួងកិច្ចការនារី<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| នឹងទីកន្លែងផ្សេងៗ | រៀបចំនិងអនុវត្ត | | • ក្រសួងព័ត៌មាន<br>• ក្រសួងធម្មការនិងសាសនា<br>• ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | |
| ២. រៀបចំដំណើរការសម្របសម្រួលភ្ជាប់តួអង្គពាក់ព័ន្ធសំខាន់ៗ (ផ្នែកអប់រំ ទេសន្តរប្រវេសន៍ អំពើជួញដូរមនុស្ស និយោជក មេដឹកនាំសាសនា តំណាងក្រុមជនងាយរងគ្រោះ តួអង្គវិស័យសាធារណៈ ឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត) ដោយប្រើប្រាស់វិធីសាស្ត្រសម្របសម្រួល សម្រាប់ការបង្ការ ទប់ស្កាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី រួមទាំងស្ត្រីដែលមានហានិភ័យខ្ពស់ឬងាយរងគ្រោះ | ក. ចំនួនកិច្ចប្រជុំនៃកិច្ចសហការអន្តរវិស័យស្តីពី ការបង្ការ ទប់ស្កាត់<br>ខ. ចំនួនស្ត្រីដែលមានហានិភ័យខ្ពស់ឬងាយរងគ្រោះ ដែលបានចូលរួមក្នុងដំណើរការសម្របសម្រួល | - ដំណើរការ/យន្តការសម្របសម្រួលបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីគ្រប់ទម្រង់មានដំណើរការសម្រាប់ការធ្វើផែនការនិងអនុវត្តយុទ្ធសាស្ត្របង្ការ ទប់ស្កាត់នានា<br>- ដំណើរការសម្របសម្រួលគ្រប់ជ្រុងជ្រោយដើម្បីបង្ការទប់ស្កាត់ ត្រូវបានបង្កើតឡើង ដោយបញ្ចូលក្រុមស្ត្រីដែលមានហានិភ័យខ្ពស់ឬងាយរងគ្រោះ | • ក្រសួងកិច្ចការនារី<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងព័ត៌មាន<br>• ក្រសួងធម្មការនិងសាសនា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ៣. ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្តីពី | ក. ចំនួនសមាជិកក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលមានសមត្ថភាពនិងចំណេះ ដឹងទាក់ទងនឹងការ | - សមាជិកក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ជាតិនិងក្រោមជាតិមានសមត្ថភាព | • ក្រសួងកិច្ចការនារី<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងមហាផ្ទៃ | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ផ្តត់គំនិតយេនឌ័រ ការផ្លាស់ប្តូរបទដ្ឋានសង្គម ការអនុវត្តល្អៗក្នុងការបង្ការ ទប់ស្កាត់បឋមនៃអំពើហិង្សាលើស្ត្រី ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះនិងប្រធានបទពាក់ព័ន្ធដទៃទៀតទាក់ទងនឹងរបៀបបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រី រួមទាំងក្រុមស្ត្រីដែលមានហានិភ័យខ្ពស់និងងាយរងគ្រោះ | អនុវត្តក្នុងការបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រី កាន់តែល្អប្រសើរឡើង<br><br>ខ. ចំនួនសកម្មភាពបង្ការ ទប់ស្កាត់ដែលមានការសម្របសម្រួលបានអនុវត្តតាមទីកន្លែងនីមួយៗ | ក្នុងការអនុវត្តនិងការសម្របសម្រួលនៃកិច្ចអន្តរាគមន៍បង្ការ ទប់ស្កាត់ ប្រកបដោយគុណភាពនិងប្រសិទ្ធភាព | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងព័ត៌មាន<br>• ក្រសួងធម្មការនិងសាសនា<br>• អាជ្ញាធរថ្នាក់ក្រោមជាតិ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | |
| ៤. ជំរុញការចូលរួមរបស់វិស័យឯកជនក្នុងសកម្មភាពបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រីពលករទេសន្តរប្រវេសន៍ | - ចំនួនក្រុមហ៊ុនឯកជនដែលចូលរួមក្នុងសកម្មភាពបង្ការ ទប់ស្កាត់ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព | - សកម្មភាពក្នុងការបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រីពលករទេសន្តរប្រវេសន៍របស់ វិស័យឯកជនត្រូវបានអនុវត្ត ដោយក្រុមហ៊ុនឯកជន | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• វិស័យឯកជន<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

**៣.២.១.២. ការអប់រំនិងយុវជន**

លទ្ធផលទី២ : មនុស្សវ័យជំទង់និងយុវជន កាន់តែមានចំណេះដឹងនិងជំនាញក្នុងការលើកកម្ពស់និងកសាងទំនាក់ទំនងប្រកបដោយសមភាពយេនឌ័រ សមធម៌យេនឌ័រ និងអហិង្សា ដើម្បីផ្លាស់ប្តូរឥរិយាបថ អាកប្បកិរិយា និងការអនុវត្តដោយគោរពសិទ្ធិមនុស្ស(រួមមានសិទ្ធិផ្លូវភេទ សមភាពយេនឌ័រ និងទំនាក់ទំនងផ្លូវភេទ)។

សូចនាករលទ្ធផល :

២ក. ឥរិយាបថមនុស្សវ័យជំទង់និងយុវជនចំពោះអំពើហិង្សាលើស្ត្រី មានការផ្លាស់ប្តូរជាវិជ្ជមាន

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេលមធ្យម | រយៈពេលវែងលើសពី | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | ៣-៥ ឆ្នាំ | ៥ឆ្នាំ | |
| ១. ពង្រីកការអនុវត្តឧបករណ៍បណ្តុះបណ្តាលសម្រាប់កម្មវិធីអប់រំពាក់ព័ន្ធនឹងសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ( សិទ្ធិទាក់ទងនឹងការរួមភេទ សមភាពយេនឌ័រ ទំនាក់ទំនងប្រកបដោយផាសុកភាព។ល។) ដល់ក្លិបកុមារសម្រាប់ក្រុមមនុស្សវ័យជំទង់ថ្មីៗ សម្រាប់សហគមន៍នៅតាមសាលានិងកន្លែងដទៃទៀត | ក. ចំនួនមនុស្សវ័យជំទង់និងយុវជន ដែលទទួលបានការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រព័ន្ធ(អាយុពី១៥ដល់២៥ឆ្នាំ)<br><br>ខ. ការផ្លាស់ប្តូរជាវិជ្ជមានរបស់សិក្ខាកាមទាំងក្នុងនិងក្រៅប្រព័ន្ធលើចំណេះដឹង ឥរិយាបថ និងការអនុវត្តទាក់ទងនឹងសិទ្ធិនៃការរួមភេទ សមភាពយេនឌ័រ ទំនាក់ទំនងប្រកបដោយផាសុកភាព | - អន្តរាគមន៍បង្ការ ទប់ស្កាត់ត្រូវបានអនុវត្តជាមួយមនុស្សវ័យជំទង់និងយុវជនទាំងក្នុងនិងក្រៅប្រព័ន្ធ | • ក្រសួងកិច្ចការនារី<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• សហភាពសហព័ន្ធយុវជនកម្ពុជា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ២. ផ្តល់ការបណ្តុះបណ្តាលដល់ក្មេងប្រុសនិងក្មេងស្រីវ័យជំទង់ ក្នុងក្លិបកុមារ ក្រុមសហគមន៍ និងក្នុងក្រុមគោលដៅលើប្រធានបទអំពើហិង្សាលើស្ត្រីដោយប្រើប្រាស់ឧបករណ៍ដែលបានកំណត់ឬបង្កើត | ក. ការផ្លាស់ប្តូរចំណេះដឹង ឥរិយាបថ និងការអនុវត្តអំពីសមធម៌យេនឌ័ររបស់សិក្ខាកាមដែលបានចូលរួមវគ្គបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រព័ន្ធ<br><br>ខ. ចំនួនក្មេងប្រុសនិងក្មេងស្រីវ័យជំទង់ដែលទទួលបានការបណ្តុះបណ្តាលទាំងក្នុងនិង | - អន្តរាគមន៍បង្ការ ទប់ស្កាត់បឋម បានអនុវត្តដោយផ្តោតលើមនុស្សវ័យជំទង់លើការអប់រំទាំងក្នុងនិងក្រៅប្រព័ន្ធ | • ក្រសួងកិច្ចការនារី<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងបរិស្ថាន<br>• សហភាពសហព័ន្ធយុវជនកម្ពុជា<br>• អង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ក្រៅប្រព័ន្ធ។ | | • វិស័យឯកជន<br>• ដៃគូពាក់ព័ន្ធ | | | | |
| ៣. បង្កើនការអនុវត្តវិធីសាស្ត្រមិត្តអប់រំមិត្ត ដោយប្រើប្រាស់ឧបករណ៍ដែលអាចចែករំលែកសារអប់រំសំខាន់ៗ ដើម្បីបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រ | ក. ចំនួនក្រុមមិត្តអប់រំមិត្ត ដែលបានបណ្តុះបណ្តាល<br><br>ខ. ចំណេះដឹង ឥរិយាបថ និងការអនុវត្តអំពីសមធម៌យេនឌ័រមានការផ្លាស់ប្តូរវិជ្ជមាន | - កិច្ចអន្តរាគមន៍តាមរយៈក្រុមមិត្តអប់រំមិត្ត ដែលផ្តោតសំខាន់លើក្មេងប្រុសវ័យជំទង់ឱ្យមានការផ្លាស់ប្តូរចំណេះដឹង ឥរិយាបថ និងការអនុវត្តអំពីសមធម៌យេនឌ័រត្រូវបានអភិវឌ្ឍនិងអនុវត្ត | • ក្រសួងកិច្ចការនារី<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• សហភាពសហព័ន្ធយុវជនកម្ពុជា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

**៣.២.១.៣. គ្រួសារនិងកូនៗ**

លទ្ធផលទី៣ **:** ចំណេះដឹង ការយល់ដឹង និងជំនាញទាក់ទងនឹងការចិញ្ចឹមកូនបែបវិជ្ជមានរបស់ឪពុកម្តាយ ដើម្បីកសាងគ្រួសារនិងបរិយាកាសប្រកបដោយសុវត្ថិភាព សមធម៌យេនឌ័រ និងអហិង្សា មានភាពប្រសើរឡើង

សូចនាករលទ្ធផល :

៣ក. យុទ្ធសាស្ត្រការចិញ្ចឹមកូនបែបវិជ្ជមាន ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេលមធ្យម ៣-៥ ឆ្នាំ | រយៈពេលវែងលើសពី ៥ ឆ្នាំ | |
| ១. ផ្តល់ការគាំទ្រនិងកិច្ចអន្តរាគមន៍នានាដល់ប្រពន្ធប្តី ដើម្បីធ្វើឱ្យ | ក. ចំនួនប្រពន្ធប្តី ជាពិសេសបុរសដែលបានចូលរួមក្នុងកិច្ច | - កិច្ចអន្តរាគមន៍ដើម្បីលើកកម្ពស់ភាពអង់អាចដល់ស្ត្រី | • ក្រសួងកិច្ចការនារី<br>• ក្រសួងអប់រំ យុវជន និង | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ប្រសើរឡើងនូវជំនាញក្នុងការដោះស្រាយបញ្ហាដោយការប្រាស្រ័យទាក់ទងបែបអហិង្សា ការដោះស្រាយវិវាទ ការកសាងទំនាក់ទំនងនិងបំណិនជីវិត ដែលធ្វើឱ្យពួកគាត់អាចលើកកម្ពស់នូវទំនាក់ទំនងប្រកបដោយសមធម៌យេនឌ័រ ផាសុកភាព មានការគោរពគ្នា និងក្នុងភាពអហិង្សា ព្រមទាំងចេះគាំទ្រដល់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី | អន្តរាគមន៍នានា<br><br>ខ. ការផ្លាស់ប្តូរឥរិយាបថដែលលើកកម្ពស់ដល់ទំនាក់ទំនងប្រកបដោយផាសុកភាពនិងអហិង្សា<br><br>គ. ចំនួនស្ថាប័នដែលចូលរួមក្នុងកិច្ចអន្តរាគមន៍និងចំនួនកិច្ចអន្តរាគមន៍ | សម្រាប់ទំនាក់ទំនងប្រកបដោយសមធម៌យេនឌ័រ សម្រាប់គូស្វាមីភរិយា ត្រូវបានរំលេចនៅក្នុងកម្មវិធីផ្សេងៗ ដូចជាផែនការគ្រួសារ និងការប្រឹក្សាយោបល់សម្រាប់ប្រពន្ធប្តី ឬគូស្នេហ៍មុនពេលរៀបការ និងដៃគូស្និទ្ធស្នាល | កីឡា<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងមហាផ្ទៃ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | |
| ២. ពង្រីកការអនុវត្តយុទ្ធសាស្ត្រនៃការចិញ្ចឹមកូនបែបវិជ្ជមាន(កុមារគ្រប់រូបពីអាយុ០ដល់១៨ឆ្នាំ)នៅក្នុងតំបន់គោលដៅថ្មី(ដោយផ្តោតលើការជំរុញការចូលរួមទាំងបុរសនិងស្ត្រី) | ក. ចំនួនកិច្ចអន្តរាគមន៍នៃការចិញ្ចឹមកូនបែបវិជ្ជមាន បានពង្រីកវិសាលភាពនៅតំបន់គោលដៅថ្មី<br><br>ខ. ចំនួនឪពុកម្តាយ ពិសេសបុរសដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល មានការរីកចម្រើនផ្នែកចំណេះដឹងនិងជំនាញផ្សេងៗ ជាពិសេសគឺអហិង្សា | - យុទ្ធសាស្ត្រនិងឧបករណ៍នានាទាក់ទងនឹងការចិញ្ចឹមកូនបែបវិជ្ជមាន ត្រូវបានអនុវត្តនៅក្នុងតំបន់គោលដៅថ្មី ដោយមានការកើនឡើងនូវការចូលរួមរបស់បុរស | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងសុខាភិបាល<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| **៣.២.១.៤. សហគមន៍និងកន្លែងធ្វើការ**<br>លទ្ធផលទី៤ : បរិយាកាសកន្លែងធ្វើការនិងសហគមន៍មានសុវត្ថិភាពនិងគ្មានការបៀតបៀនគ្រប់រូបភាព ត្រូវបានលើកកម្ពស់ | | | | | | | |

| សូចនាករលទ្ធផល :<br>៤ក. ឥរិយាបថដែលទទួលយកអំពើបៀតបៀន អំពើហិង្សា និងការរំលោភបំពានសិទ្ធិនៅតាមកន្លែងធ្វើការងារនិងក្នុងសហគមន៍ ត្រូវបានផ្លាស់ប្តូរ | | | | | | | |
|---|---|---|---|---|---|---|---|
| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេល មធ្យម ៣-៥ ឆ្នាំ | រយៈពេល វែងលើសពី ៥ ឆ្នាំ | |
| ១. កៀរគរការចូលរួមពីសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីរៀបចំនិងអនុវត្តលើកិច្ចអន្តរាគមន៍បង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រី ទាំងនៅក្នុងវិស័យសាធារណៈនិងឯកជន និងដោយរួមបញ្ចូលទាំងក្រុមស្ត្រីដែលមានហានិភ័យខ្ពស់ឬងាយរងគ្រោះ | ក. ចំនួនសកម្មភាពបង្ការ ទប់ស្កាត់ ដែលបានអនុវត្តនៅកន្លែងធ្វើការ(ស្ថាប័នរដ្ឋនិងឯកជន)<br>ខ. ចំនួនក្រុមផ្សេងៗគ្នា(សាធារណៈ និងឯកជន)ដែលត្រូវបានកៀរគរនិងចូលរួមសកម្មភាពបង្ការ ទប់ស្កាត់<br>គ. ចំនួនសកម្មភាពរួមគ្នា ដែលដោះស្រាយការបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រី ជាមួយក្រុមស្ត្រីដែលមានហានិភ័យខ្ពស់ឬងាយរងគ្រោះ | - អ្នកផ្តល់សេវាសាធារណៈ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ រួមទាំងក្រុមស្ត្រី ក្រុមកម្មករ និយោជិត ក្រុមសាសនា និងអ្នកស្ម័គ្រចិត្ត ត្រូវបានកៀរគរចូលរួមនិងមានធនធានដើម្បីដឹកនាំសកម្មភាពសហគមន៍ ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផ្លាស់ប្តូរផ្នត់គំនិតអវិជ្ជមានដែលមានក្នុងសង្គម | • ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងទេសចរណ៍<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងធម្មការនិងសាសនា<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ២. បង្កើនកម្មវិធីអភិវឌ្ឍជំនាញនិងកម្មវិធីបង្កើតប្រាក់ចំណូលដើម្បី | ក. ចំនួនកម្មវិធីថ្មីផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីសម្រាប់ | - កម្មវិធីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី របស់ | • ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| លើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី(កម្មវិធីដែលធ្វើឱ្យស្ត្រីមានលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ ចេះគ្រប់គ្រងធនធាន បង្កើតប្រាក់ចំណូលនិងទ្រព្យសម្បត្តិ បង្កើនប្រាក់សន្សំ និងភាពអង់អាចក្នុងការធ្វើសេចក្តីសម្រេចផ្នែកហិរញ្ញវត្ថុនិងឯករាជ្យភាពផ្នែកសេដ្ឋកិច្ច)សំដៅចូលរួមកាត់បន្ថយអំពើហិង្សាលើស្ត្រី | ស្ត្រីគ្រប់រូបដែលរងគ្រោះដោយអំពើហិង្សាលើស្ត្រី<br><br>ខ. ចំនួនក្រសួង ស្ថាប័ន សង្គមស៊ីវិល និងវិស័យឯកជនចូលរួមទប់ស្កាត់អំពើហិង្សាលើស្ត្រី តាមរយៈការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | រាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនបានចូលរួមចំណែកកាត់បន្ថយអំពើហិង្សាលើស្ត្រី<br><br>- រាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ផ្តល់អាទិភាពលើការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី តាមរយៈការពង្រីកការបង្កើតកម្មវិធី ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | • ក្រសួងទេសចរណ៍<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ក្រសួងបរិស្ថាន<br>• ក្រសួងពាណិជ្ជកម្ម<br>• ក្រសួងអភិវឌ្ឍន៍ជនបទ<br>• គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>• ធនាគារជាតិនៃកម្ពុជា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | |
| ៣. បង្កើតនិងអនុវត្តគោលនយោបាយ ពិធីសារនិងយន្តការស្តីពីការលុបបំបាត់ការបៀតបៀននៅកន្លែងធ្វើការតាមស្ថាប័នរដ្ឋនិងឯកជន | គ. ចំនួនគោលនយោបាយពិធីសារ និងយន្តការស្តីពីការលុបបំបាត់ការបៀតបៀននិងអំពើហិង្សាលើស្ត្រីនៅកន្លែងធ្វើការ តាម | - ស្ថាប័នរាជរដ្ឋាភិបាល សមាគមរោងចក្រកាត់ដេរកម្ពុជា(GMAC)និយោជក (ទាំងក្នុងប្រព័ន្ធនិងក្រៅ | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ស្ថាប័នរដ្ឋនិងឯកជន ដែលបានបង្កើត<br><br>ខ. ចំនួនកន្លែងធ្វើការ ដែលអនុវត្តគោលនយោបាយ ពិធីសារ និងយន្តការដែលបានបង្កើត | ប្រព័ន្ធ និងសហជីពកម្មករបានអនុវត្តតាមការព្រមព្រៀងលើគោលនយោបាយពិធីសារ និងយន្តការនានាសម្រាប់កម្មវិធីកន្លែងធ្វើការមានសុវត្ថិភាពនិងគ្មានការបៀតបៀន | • ក្រសួងទេសចរណ៍<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | |
| ៤. លើកកម្ពស់បរិយាកាសកន្លែងធ្វើការមានសុវត្ថិភាព គ្មានការបៀតបៀន មានការគោរពគ្នាតាមរយៈការបង្កើនការយល់ដឹងអំពីសិទ្ធិការងារ ហានិភ័យនៃអំពើហិង្សានៅកន្លែងធ្វើការ និងកិច្ចការពារផ្សេងៗដែលចាំបាច់ | ក. ចំនួនស្ថាប័នរាជរដ្ឋាភិបាល សមាគមរោងចក្រកាត់ដេរកម្ពុជា(GMAC)និយោជកទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ និងសហជីពកម្មករ ដែលបានពង្រឹងសមត្ថភាព លើគោលនយោបាយ ពិធីសារ និងយន្តការនានា ដើម្បីបង្ការទប់ស្កាត់ និងការពារអំពើហិង្សាលើស្ត្រី<br>ខ. ចំនួនករណីការបៀតបៀននៅកន្លែងធ្វើការដែលបានរាយការណ៍និងឆ្លើយតបយ៉ាងសមស្រប | - បរិយាកាសកន្លែងធ្វើការមានសុវត្ថិភាព និងគ្មានការបៀតបៀនគ្រប់រូបភាពត្រូវបានលើកកម្ពស់ ទាំងនៅក្នុងស្ថាប័ន រាជរដ្ឋាភិបាល និងវិស័យឯកជន | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងទេសចរណ៍<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៥. បង្កើនការយល់ដឹងអំពីបញ្ហាប្រឈមនិងការអនុវត្តល្អៗ ក្នុងការ | - ចំនួនសកម្មភាព/ការអនុវត្តជាក់ស្តែងដែលត្រូវបានកំណត់ក្នុង | - របាយការណ៍គ្រប់ជ្រុងជ្រោយស្តីពីការអនុវត្តល្អៗ | • ក្រសួងកិច្ចការនារី<br>• ក្រសួងសង្គមកិច្ច អតីត | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងស្ត្រីពលករទេសន្តរប្រវេសន៍ | សិក្ខាសាលាប្រចាំឆ្នាំ | និងបញ្ហាប្រឈមក្នុងការបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងស្ត្រីពលករទេសន្តរប្រវេសន៍ ត្រូវបានបង្កើត និងផ្សព្វផ្សាយ | យុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងមហាផ្ទៃ<br>• គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | |
| ៦. លើកកម្ពស់ការចូលរួមរបស់បុរសនៅគ្រប់កម្រិត ( នៅកន្លែងធ្វើការ លំនៅឋាន និងសហគមន៍ ) ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី (កម្មវិធីបុរសល្អ ចូលរួមទប់ស្កាត់អំពើហិង្សាលើស្ត្រី។ល។) | ក- ចំនួនកម្មវិធីនិងយុទ្ធនាការដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី<br>ខ- ចំនួនបុរសដែលចូលរួមក្នុងកម្មវិធីនិងយុទ្ធនាការដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី | - បុរសចូលរួមក្នុងការបញ្ឈប់អំពើហិង្សាលើស្ត្រី តាមរយៈកិច្ចខិតខំប្រឹងប្រែងនានា | • ក្រសួងមហាផ្ទៃ<br>• ក្រសួងការពារជាតិ<br>• ក្រសួងទេសចរណ៍<br>• ក្រសួងព័ត៌មាន<br>• ក្រសួងពាណិជ្ជកម្ម<br>• ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• ក្រសួងបរិស្ថាន<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៧. បង្កើតនិងអនុវត្តកម្មវិធីដើម្បីលើកកម្ពស់ភាពជាបុរសល្អ(បុរសដែលមិនប្រើប្រាស់ហិង្សា) | ក. ចំនួនកម្មវិធីដែលផ្តោតលើការលើកកម្ពស់ភាពជាបុរសល្អ<br>ខ. ចំនួនបុរសដែលបានចូលរួមលើកកម្ពស់ភាពជាបុរសល្អ | - ឥរិយាបថនិងការប្រព្រឹត្តរបស់បុរសមានការផ្លាស់ប្តូរស្របតាមគោលបំណងដែលបានកំណត់ក្នុងកម្មវិធីបុរសល្អ (ឧទាហរណ៍: | • ក្រសួងកិច្ចការនារី<br>• ក្រសួងការពារជាតិ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | គ. ឥរិយាបថនិងអាកប្បកិរិយា មានការផ្លាស់ប្តូរតាមវិស័យគោលដៅសំខាន់ៗ | ការប្រើប្រាស់គ្រឿងស្រវឹង ប្រកបដោយសុវត្ថិភាព អហិង្សាក្នុងទំនាក់ទំនង លើកកម្ពស់សមភាពយេនឌ័រនៅក្នុងការងារនិងជីវិតផ្ទាល់ខ្លួន...) | | | | | |
| ៨. ផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិ (ឧទាហរណ៍ : ការរស់នៅដោយគ្មានអំពើហិង្សា កិច្ចការពារនានាចំពោះកម្មករ) ក្នុងការបង្កើនការយល់ដឹងអំពីកិច្ចការពារ ដើម្បីការពារដល់ស្ត្រីពលករទេសន្តរប្រវេសន៍ | ក. ចំនួនយុទ្ធនាការ/កម្មវិធីអប់រំ និងការផ្សព្វផ្សាយអំពីសិទ្ធិសម្រាប់ស្ត្រីពលករទេសន្តរប្រវេសន៍<br>ខ. ចំនួនពលករទេសន្តរប្រវេសន៍ និងអ្នកចូលរួមពាក់ព័ន្ធដែលបានទទួលព័ត៌មាននិងចំណេះដឹងអំពីសិទ្ធិនៃពលករទេសន្តរប្រវេសន៍ | - ព័ត៌មានអំពីសិទ្ធិក្នុងការទទួលបានកិច្ចការពាររបស់ស្ត្រីពលករទេសន្តរប្រវេសន៍ ត្រូវបានផ្សព្វផ្សាយដល់ពលករទេសន្តរប្រវេសន៍និងភាគីពាក់ព័ន្ធដទៃទៀត<br>- ស្ត្រីពលករទេសន្តរប្រវេសន៍ និងភាគីពាក់ព័ន្ធដទៃទៀតយល់អំពីសិទ្ធិនិងកិច្ចការពាររបស់ពួកគាត់ | • ក្រសួងកិច្ចការនារី<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

**៣.២.១.៥. វប្បធម៌និងប្រព័ន្ធផ្សព្វផ្សាយ**

លទ្ធផលទី៥ **:** ការលើកកម្ពស់សមភាពយេនឌ័រ បទដ្ឋានសង្គមបែបអហិង្សា សារអប់រំ និងសមត្ថភាពរបស់ប្រព័ន្ធផ្សព្វផ្សាយ រួមទាំងបណ្តាញផ្សព្វផ្សាយសង្គមក្នុងការយកចិត្តទុកដាក់ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី មានការកើនឡើង

សូចនាករលទ្ធផល :

៥ក. ចំនួនក្រុមគោលដៅចូលរួមយុទ្ធនាការផ្សព្វផ្សាយដែលបានបង្ហាញពីការផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនចំពោះអំពើហិង្សាលើស្ត្រី

៥ខ. ពាក្យសម្តីមិនសមរម្យឬពាក្យសម្តីដែលមានលក្ខណៈរិសមភាពយេនឌ័រតាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាព ត្រូវបានកាត់បន្ថយ

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|

| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេលមធ្យម ៣-៥ ឆ្នាំ | រយៈពេលវែងលើសពី ៥ ឆ្នាំ | |
|---|---|---|---|---|---|---|---|
| ១. រៀបចំយុទ្ធសាស្ត្រការប្រាស្រ័យទាក់ទង តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដោយមានសារអប់រំគន្លឹះរួម សម្រាប់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់បទដ្ឋានជាវិជ្ជមានរបស់សង្គមនិងបទដ្ឋានយេនឌ័រ | - ចំនួនវិទ្យុ ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយសង្គម ប្រព័ន្ធផ្សព្វផ្សាយឯកសារបោះពុម្ព ឧបករណ៍ សម្ភារៈ ឬយុទ្ធនាការនានា ដែលបានធ្វើការផ្សព្វផ្សាយក្នុងការលើកកម្ពស់បទដ្ឋានសង្គមនិងយេនឌ័រវិជ្ជមាន ដែលមិនអត់ធ្មត់ចំពោះករណីអំពើហិង្សាលើស្ត្រី ដោយរាប់បញ្ចូលទាំងទម្រង់ថ្មីៗនៃអំពើហិង្សា ការបៀតបៀនផ្លូវភេទ និងការសម្លុតតាមប្រព័ន្ធអ៊ីនធឺណិត | - ព័ត៌មានគ្រប់ជ្រុងជ្រោយយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង និងយុទ្ធនាការផ្សព្វផ្សាយត្រូវបានរៀបចំនិងអនុវត្ត | • ក្រសួងព័ត៌មាន<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>• ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងទេសចរណ៍<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ២. លើកកម្ពស់ការយល់ដឹងនិងការអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រីនិងធ្វើការតាមដាននិងពិនិត្យប្រព័ន្ធផ្សព្វផ្សាយ | ក. ចំនួនអ្នកសារព័ត៌មានដែលទទួលការបណ្តុះបណ្តាលអំពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រីនិងបានផ្សព្វផ្សាយការទប់ស្កាត់អំពើហិង្សាលើស្ត្រី | - អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយបានបង្កើនសមត្ថភាពក្នុងការធ្វើសេចក្តីរាយការណ៍ពីករណីអំពើហិង្សាលើស្ត្រី ស្របតាមក្រមប្រតិបត្តិសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ | • ក្រសួងព័ត៌មាន<br>• ក្រសួងទេសចរណ៍<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>• ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ខ. ចំនួនឯកសារស្តីពីការរាយការណ៍ពីករណីអំពើហិង្សាលើស្ត្រីដែលត្រូវបានផ្សព្វផ្សាយ | | • ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | |
| ៣. ផ្តល់ការបណ្តុះបណ្តាលស្តីពីសារគន្លឹះទាក់ទងនឹងអំពីហិង្សាលើស្ត្រីដល់អ្នកដឹកនាំនិងភ្នាក់ងារសាសនា | ក. ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់អ្នកដឹកនាំនិងភ្នាក់ងារសាសនា<br><br>ខ. ចំនួនអ្នកដឹកនាំនិងភ្នាក់ងារសាសនាដែលចូលរួមក្នុងសកម្មភាពបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី | - អ្នកដឹកនាំនិងភ្នាក់ងារសាសនាដើរតួនាទីជាមនុស្សគំរូនៅក្នុងសហគមន៍របស់ពួកគាត់ក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី<br>- អ្នកដឹកនាំនិងភ្នាក់ងារសាសនាបានបង្កើនសមត្ថភាពដើម្បីចែករំលែកសារអប់រំវិជ្ជមានអំពីសមភាពយេនឌ័រនិងទប់ស្កាត់អំពើហិង្សាលើស្ត្រី | • ក្រសួងធម្មការនិងសាសនា<br>• ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ៤. ធ្វើយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយដើម្បីជានាការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ សិទ្ធិរបស់ស្ត្រីចំពោះជីវិតរស់នៅដោយគ្មានអំពើហិង្សា | - ចំនួនយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ | - សាធារណជនទូទៅ មានការយល់ដឹងប្រសើរជាងមុន ដែលថា អំពើហិង្សាលើស្ត្រី គឺជាអំពើខុសច្បាប់ ហើយយល់ដឹងពីសិទ្ធិរបស់ស្ត្រីចំពោះជីវិតរស់នៅដោយគ្មានអំពើហិង្សា | • ក្រសួងធម្មការនិងសាសនា<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល<br>• ក្រសួងព័ត៌មាន<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងប្រៃសណីយ៍និង | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ទូរគមនាគមន៍ | | | | |
| ៥. សម្របសម្រួលរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ការយល់ដឹងដល់អ្នកសារព័ត៌មាន អំពី អំពើហិង្សាលើស្ត្រីនិងក្រុមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍អំពើហិង្សាលើស្ត្រី | - ចំនួនប្រព័ន្ធផ្សព្វផ្សាយដែលគោរពសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ ស្របតាមក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយ | - អ្នកសារព័ត៌មានកាន់តែមានការយល់ដឹងក្នុងការសរសេរសេចក្តីរាយការណ៍និងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងស្ត្រីដែលរងអំពើហិង្សា | • ក្រសួងព័ត៌មាន<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ៦. រៀបចំសិក្ខាសាលាអន្តរសាសនានៅថ្នាក់ជាតិដើម្បីបង្កើនការយល់ដឹងនិងការចូលរួមពីអ្នកដឹកនាំនិងភ្នាក់ងារសាសនានានា ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី | ក. ចំនួនអ្នកដឹកនាំនិងភ្នាក់ងារសាសនានានាចូលរួមក្នុងវេទិកា<br>ខ. ចំនួនវេទិកាដែលបានរៀបចំ | - អ្នកដឹកនាំនិងភ្នាក់ងារសាសនានានាបានចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី | • ក្រសួងធម្មការនិងសាសនា<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ៧. បណ្តុះបណ្តាលដល់មន្ត្រីជំនាញនៅតាមក្រសួងពាក់ព័ន្ធ អំពីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) | - ចំនួនមន្ត្រីពាក់ព័ន្ធមានការកើនឡើងនូវចំណេះដឹងអំពីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) និងគោលការណ៍ | - មន្ត្រីបច្ចេកទេសនៅតាមបណ្តាក្រសួងពាក់ព័ន្ធ បានបង្កើនចំណេះដឹងរបស់ខ្លួនអំពីការរើសអើងនឹងនារីភេទ និងអាចអនុវត្តគោលការណ៍អនុសញ្ញាស្តីពីការ | • ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី (CNCW)<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

<table>
<tr><td></td><td>ណែនាំ</td><td>លុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW)</td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="8">៣.២.២. យុទ្ធសាស្ត្រទី២ : កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ<br>គោលបំណង : ដើម្បីបង្កើនការផ្តល់សេវា ដែលអាចទទួលយកបានសមស្រប និងការសម្របសម្រួលក្នុងការផ្តល់សេវាប្រកបដោយគុណភាព និងការឆ្លើយតបទៅតាមតម្រូវការផ្សេងៗរបស់ស្ត្រីគ្រប់រូបដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។</td></tr>
<tr><td colspan="8">៣.២.២.១. ការសម្របសម្រួលពហុវិស័យ<br>លទ្ធផលទី៦ : ការសម្របសម្រួលនិងភ្ជាប់ទំនាក់ទំនងរវាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ អ្នកផ្តល់សេវា និងសង្គមស៊ីវិលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវបានបង្កើន<br>សូចនាករលទ្ធផល :<br>៦ក. ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា និងសង្គមស៊ីវិល បានបង្កើនការផ្តល់និងចែករំលែកព័ត៌មាន និងបញ្ជូនស្ត្រីរងគ្រោះដោយអំពើហិង្សាទៅរកសេវាចាំបាច់បានល្អប្រសើរជាងមុន</td></tr>
<tr><td rowspan="2">សកម្មភាព</td><td rowspan="2">សូចនាករ</td><td rowspan="2">លទ្ធផលរំពឹងទុក</td><td rowspan="2">ស្ថាប័នទទួលខុសត្រូវ</td><td colspan="3">រយៈពេល</td><td rowspan="2">ប្រភពធនធាន</td></tr>
<tr><td>រយៈពេលខ្លី ១-២ ឆ្នាំ</td><td>រយៈពេលមធ្យម ៣-៥ ឆ្នាំ</td><td>រយៈពេលវែងលើសពី ៥ ឆ្នាំ</td></tr>
<tr><td colspan="8">ថ្នាក់ជាតិ៖</td></tr>
<tr><td>១. ពិនិត្យនិងធ្វើបច្ចុប្បន្នកម្មលើតួនាទីភារកិច្ច ការទទួលខុសត្រូវ និងសមាជិកភាពនៃក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV)<br>២. រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ TWGG-GBV ដើម្បីលើកកម្ពស់ការ</td><td>ក. តួនាទីភារកិច្ច ការទទួលខុសត្រូវ និងសមាជិកភាពនៃក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) ដែលបានធ្វើបច្ចុប្បន្នកម្មនិងអនុវត្ត</td><td>- ក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) ដែលជាយន្តការសម្របសម្រួលពហុវិស័យថ្នាក់ជាតិ ក្នុងការដឹកនាំការសម្របសម្រួលដើម្បីអនុវត្ត NAPVAW ត្រូវ</td><td>• លេខាធិការដ្ឋាននៃក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV)</td><td>X</td><td></td><td></td><td>រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ</td></tr>
</table>

| | | | | | | | |
|---|---|---|---|---|---|---|---|
| ធ្វើផែនការ ការសម្របសម្រួល ការត្រួតពិនិត្យ និងការចែករំលែកព័ត៌មានអំពីការអនុវត្ត NAPVAW<br>៣. រៀបចំផែនការការងាររួមគ្នារវាងក្រសួងពាក់ព័ន្ធសំខាន់ៗ ដើម្បីអនុវត្ត NAPVAW<br>៤. រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្ត NAPVAW របស់ក្រសួង ស្ថាប័ននានា | ខ. ចំនួនផែនការសកម្មភាពការងាររួមគ្នារវាងក្រសួងពាក់ព័ន្ធសំខាន់ៗ ដែលបានបង្កើតនិងអនុវត្ត។ TWGG GBV មានផែនការប្រតិបត្តិរួមសម្រាប់អនុវត្ត NAPVAW III។<br>គ. ចំនួនកិច្ចប្រជុំរបស់ TWGG-GBV<br>ឃ. ចំនួនរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត NAPVAW របស់ក្រសួង ស្ថាប័ននានា | បានពង្រឹងនិងបានដំណើរការប្រកបដោយប្រសិទ្ធភាព<br>- របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្ត NAPVAW ត្រូវបានពង្រឹងនិងចែករំលែកជាសាធារណៈ | • ក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ | X<br>X | X<br>X | X<br>X | |
| • ថ្នាក់ខេត្ត៖ | | | | | | | |
| ៥. ពិនិត្យនិងធ្វើបច្ចុប្បន្នកម្មលើតួនាទីភារកិច្ច ការទទួលខុសត្រូវ និងសមាជិកភាពនៃក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្ត (PWG-GBV)<br>៦. ពង្រីកចំនួននិងបង្កើនសមត្ថភាពក្រុមការងារឆ្លើយតបជាពហុវិស័យ | ក. តួនាទី ភារកិច្ច ការទទួលខុសត្រូវ និងសមាជិកភាពនៃក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្ត (PWG-GBV) ដែលបានធ្វើបច្ចុប្បន្នកម្មនិងអនុវត្ត។ | - ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្ត (PWG-GBV) ដែលជាយន្តការសម្របសម្រួលពហុវិស័យ ក្នុងការដឹកនាំការសម្របសម្រួលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្ត | • ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្ត (PWG-GBV) | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ<br>៧. រៀបចំផែនការការងាររួមគ្នារវាងមន្ទីរពាក់ព័ន្ធសំខាន់ៗ ដើម្បីអនុវត្ត NAPVAW<br>៨. រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ PWG-GBV ដើម្បីលើកកម្ពស់ការធ្វើផែនការ ការសម្របសម្រួល ការត្រួតពិនិត្យ និងការចែករំលែកព័ត៌មាន និងអន្តរាគមន៍អំពីការអនុវត្ត NAPVAW | ខ. ចំនួន PWG-GBV ដែលបានបង្កើតនិងដំណើរការ<br>គ. ចំនួនកិច្ចប្រជុំរបស់ PWG-GBV<br>ឃ. ចំនួនករណីអំពើហិង្សាលើស្ត្រីដែលបានផ្តល់កិច្ចអន្តរាគមន៍សមស្រប<br>ង. ចំនួនកិច្ចប្រជុំ PWG GBV ដែលបានរៀបចំនិងកំណត់ហេតុកិច្ចប្រជុំបានរៀបចំនិងរក្សាទុកបានត្រឹមត្រូវ | NAPVAW ត្រូវបានពង្រឹងនិងបានដំណើរការប្រកបដោយប្រសិទ្ធភាព<br>ក្រុមការងារ PWG–GBV មានផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់អនុវត្ត NAPPVAW III | | | | | |
| • ថ្នាក់ស្រុក៖ | | | | | | | |
| ៩. រៀបចំតួនាទី ភារកិច្ចរបស់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្នាក់ស្រុក (DWG-GBV) ឱ្យមានលក្ខណៈស្តង់ដានិងត្រូវអនុវត្តជាទូទៅ | ក. តួនាទី ភារកិច្ច ការទទួលខុសត្រូវនិងសមាជិកភាពសម្រាប់ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្នាក់ស្រុក (DWG-GBV) ដែលបានធ្វើបច្ចុប្បន្នកម្មនិងអនុវត្ត | - ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ស្រុក (DWG-GBV) ដែលជាយន្តការសម្របសម្រួល ត្រូវបានពង្រីកចំនួនបន្ថែមនិងពង្រឹងសមត្ថភាព | • ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្នាក់ខេត្ត (PWG-GBV)<br>• ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ខ. ចំនួនក្រុមការងារ DWG-GBV ថ្នាក់ស្រុក ដែលបានបង្កើត និងដំណើរការ | | ស្រុក (DWG-GBV) | | | | |
| ១០. បង្កើតនិងបង្កើនសមត្ថភាពក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ស្រុក | - ចំនួនក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ស្រុក ដែលបានបង្កើតនិងដំណើរការផ្អែកទៅតាមតួនាទីភារកិច្ច ការទទួលខុសត្រូវ (ToR)និងស្របតាមបទដ្ឋានអប្បបរមាស្តីពីសេវាកម្មដែលពាក់ព័ន្ធ | - ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ស្រុក មានដំណើរការល្អ និងអនុលោមតាមតួនាទីភារកិច្ច និងការទទួលខុសត្រូវ (ToR) ហើយក្លាយជាយន្តការផ្លូវការប្រកបដោយចីរភាព | • ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្នាក់ខេត្ត (PWG-GBV) | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| • ការផ្សារភ្ជាប់ទំនាក់ទំនង៖ | | | | | | | |
| ១១. ធ្វើការប៉ាន់ប្រមាណអំពីដំណើរការដែលមានស្រាប់និងការបង្កើតយន្តការនានា (តាមតម្រូវការ) សម្រាប់រាយការណ៍និងចែករំលែកព័ត៌មានរវាង TWGG-GBV, PWG, ក្រុមការងារ GBV ថ្នាក់ស្រុក | - របាយការណ៍ប៉ាន់ប្រមាណអំពីការរៀបចំយន្តការដែលផ្អែកតាមអនុសាសន៍នានា សម្រាប់រាយការណ៍និងចែករំលែកព័ត៌មានរវាងក្រុមការងារឆ្លើយតបថ្នាក់ជាតិ ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្នាក់ខេត្ត និងក្រុមការងារឆ្លើយតប | - ប្រព័ន្ធសម្រាប់រាយការណ៍ និងចែករំលែកព័ត៌មានត្រូវបានបង្កើតឡើងដើម្បីផ្សារភ្ជាប់ក្រុមការងារ GBV ថ្នាក់ជាតិ រហូតដល់ថ្នាក់ស្រុក | • ក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្នាក់ស្រុក ដែលបានផ្សព្វផ្សាយ | | | | | | |
| ១២. ផ្តល់ការបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធសំខាន់ៗ ទាក់ទងនឹងតួនាទីនិងការទទួលខុសត្រូវ បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់សេវាដែលពាក់ព័ន្ធ (សេវាចាំបាច់សុខភាព ការបញ្ជូន ការផ្តល់ប្រឹក្សាជាមូលដ្ឋាន ការសម្រុះសម្រួល...។ល។) និងការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបរិយាបន្នសម្រាប់ក្រុមដែលងាយរងគ្រោះរួមទាំងហានិភ័យនៃអំពើហិង្សាលើស្ត្រី បទពិសោធនៃការទទួលរងនូវការមាក់ងាយនិងការរើសអើង និងតម្រូវការជាក់លាក់ | ក. ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់ភាគីពាក់ព័ន្ធផ្សេងៗ<br><br>ខ. ភាគរយនៃក្រុមការងារឆ្លើយតបអំពើហិង្សាគ្រប់កម្រិតដែលបំពេញការងារតាមបទដ្ឋានអប្បបរមា | - ភាគីពាក់ព័ន្ធសំខាន់ៗមានសមត្ថភាពក្នុងការផ្តល់សេវាចាំបាច់ប្រកបដោយគុណភាពដល់ជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី | • ក្រសួងកិច្ចការនារី<br>• ក្រសួងសុខាភិបាល<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងយុត្តិធម៌<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

**៣.២.២.២. សេវាសុខាភិបាល**

លទ្ធផលទី៧ : ការឆ្លើយតបជាប្រព័ន្ធលើករណីអំពើហិង្សាលើស្ត្រីសម្រាប់ប្រព័ន្ធសុខាភិបាល កាន់តែមានភាពប្រសើរឡើង

សូចនាករលទ្ធផល :

៧ក. ចំនួនស្ត្រីដែលត្រូវបានគេកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើហិង្សានៅក្នុងប្រព័ន្ធសុខាភិបាលនិងត្រូវបានបញ្ជូនទៅរកសេវាសមស្របនានា មានការកើនឡើង

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|

| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេល មធ្យម ៣-៥ ឆ្នាំ | រយៈពេល វែងលើសពី ៥ ឆ្នាំ | |
|---|---|---|---|---|---|---|---|
| ១. ដាក់បញ្ចូលសកម្មភាពឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី ក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល | ក. ចំនួនសកម្មភាពគន្លឹះឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី ដែលត្រូវបានដាក់ចូលក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល<br><br>ខ. របាយការណ៍វឌ្ឍភាពនៃការអនុវត្តសកម្មភាពគន្លឹះឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី | - ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាលបានដាក់បញ្ចូលសកម្មភាពឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី<br>- ថវិកាសម្រាប់អនុវត្តសកម្មភាពទាក់ទងនឹងអំពើហិង្សាលើស្ត្រី ត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល | • ក្រសួងសុខាភិបាល<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ២. ផ្តល់ការបណ្តុះបណ្តាល ការតម្រង់ទិស និងការបំពាក់បំប៉នដល់បុគ្គលិកសុខាភិបាល អំពីការថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សា | ក. ចំនួនបុគ្គលិកនៅមូលដ្ឋានសុខាភិបាល ដែលបានទទួលការបណ្តុះបណ្តាលអំពី ការថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សា<br><br>ខ. ចំនួនជនរងគ្រោះដែលស្វែងរកការថែទាំផ្នែកសុខភាព | - សមត្ថភាពរបស់អ្នកផ្តល់សេវាថែទាំសុខភាព ក្នុងការកំណត់អត្តសញ្ញាណ ផ្តល់ការថែទាំ និងបញ្ជូនស្ត្រីជាជនរងគ្រោះដោយអំពើហិង្សា មានការកើនឡើង | • ក្រសួងសុខាភិបាល<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៣. អនុម័តនិងផ្សព្វផ្សាយសេចក្តី | ក. សៀវភៅណែនាំដែលបាន | - សៀវភៅណែនាំសម្រាប់ | • ក្រសួងសុខាភិបាល | X | X | X | រាជរដ្ឋាភិបាល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ណែនាំស្តីពីការថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សា ដល់អ្នកគ្រប់គ្រងសេវាសុខាភិបាល | អនុម័ត<br>ខ. ចំនួនអ្នកគ្រប់គ្រងសេវាសុខាភិបាល ដែលទទួលបានសេចក្តីណែនាំស្តីពីការថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សា | អ្នកគ្រប់គ្រងសេវាសុខាភិបាលៈ ការពង្រឹងការឆ្លើយតបពីប្រព័ន្ធសេវាសុខាភិបាល ចំពោះស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬអំពើហិង្សាផ្លូវភេទ ត្រូវបានអនុម័ត និងប្រើប្រាស់ក្នុងការបណ្តុះបណ្តាល ដល់អ្នកគ្រប់គ្រងសេវាសុខាភិបាល<br>- ចំណេះដឹងរបស់អ្នកគ្រប់គ្រងសេវាសុខាភិបាលអំពីការថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សាមានការកើនឡើង | • ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | និងដៃគូអភិវឌ្ឍ |
| ៤. ផ្តល់កញ្ចប់សម្ភារៈសម្រាប់ធ្វើកោសល្យវិច័យ ទាក់ទងនឹងការរំលោភផ្លូវភេទ និងការបណ្តុះបណ្តាលដល់គណៈកម្មាធិការកោសល្យវិច័យ/ក្រុមគ្រូពេទ្យដែលទទួលខុសត្រូវលើការធ្វើកោសល្យវិច័យអំពីផ្ទត់គំនិតយេនឌ័រ និងការផ្តល់សក្ខីកម្មនៅតុលាការ | ក. ចំនួនស្ត្រីរងគ្រោះដែលទទួលបានការធ្វើកោសល្យវិច័យ<br>ខ. ចំនួនគណៈកម្មាធិការធ្វើកោសល្យវិច័យ/ក្រុមគ្រូពេទ្យដែលទទួលខុសត្រូវលើការធ្វើកោសល្យវិច័យ ដែលទទួលបានការបណ្តុះបណ្តាល<br>គ. ចំនួនកញ្ចប់សម្ភារៈសម្រាប់ធ្វើ | - សមត្ថភាពគណៈកម្មាធិការកោសល្យវិច័យ/ក្រុមគ្រូពេទ្យដែលទទួលខុសត្រូវលើការធ្វើកោសល្យវិច័យ ត្រូវបានពង្រឹង | • ក្រសួងសុខាភិបាល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | កោសល្យវិច័យ ទាក់ទងនឹងការរំលោភផ្លូវភេទ ដែលបានផ្ដល់ | | | | | | |
| ៥. កែលម្អការប្រមូលនិងការបញ្ចូលទិន្នន័យអំពីជនរងគ្រោះដោយអំពើហិង្សានៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល | ក. ទិន្នន័យអំពីជនរងគ្រោះដោយអំពើហិង្សាបានបង្ហាញនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល<br>ខ. ចំនួនស្ត្រីរងគ្រោះដែលមកទទួលសេវាថែទាំសុខភាព<br>គ. ចំនួនស្ត្រីរងគ្រោះដែលបានបញ្ជូនពីមូលដ្ឋានសុខាភិបាលទៅរកសេវាចាំបាច់នានា | - ទិន្នន័យអំពីជនរងគ្រោះដោយអំពើហិង្សានៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលត្រូវបានកែលម្អ | • ក្រសួងសុខាភិបាល<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ៦. បង្កើតកន្លែងផ្ដល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី នៅមន្ទីរពេទ្យ | ក. ចំនួនមន្ទីរពេទ្យដែលមានកន្លែងផ្ដល់សេវាចម្រុះសម្រាប់ជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ<br>ខ. ចំនួនស្ត្រីរងគ្រោះដោយអំពើហិង្សាទទួលបានសេវាថែទាំសុខភាពនៅមន្ទីរពេទ្យដែលមានកន្លែងផ្ដល់សេវាចម្រុះ | - ស្ត្រីរងគ្រោះដោយអំពើហិង្សា ជាពិសេសអំពើហិង្សាផ្លូវភេទ ទទួលបានការថែទាំសុខភាពនិងសេវាគាំទ្រចាំបាច់ប្រសើរជាងមុន | • ក្រសួងសុខាភិបាល<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

**៣.២.២.៣. នគរបាលនិងយុត្តិធម៌**

លទ្ធផលទី៨ : ស្ត្រីគ្រប់រូបដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការទទួលបានយុត្តិធម៌

សូចនាករលទ្ធផល :

៨ក. ចំនួនជនរងគ្រោះដោយអំពើហិង្សា ដែលទទួលបានសេវាផ្លូវច្បាប់ដែលផ្ដល់ដោយមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ មានការកើនឡើង

| ៨ខ. ចំនួនសេចក្តីសម្រេច/សាលក្រមរបស់តុលាការសម្រាប់ករណីអំពើហិង្សាលើស្ត្រី មានការកើនឡើង<br>៨គ. ចំនួនជនរងគ្រោះដោយអំពើហិង្សា ដែលទទួលបាននូវសេវាជំនួយផ្លូវច្បាប់ មានការកើនឡើង<br>៨ឃ. ចំនួននៃការចេញដីកាការពារ មានការកើនឡើង | | | | | | | |
|---|---|---|---|---|---|---|---|
| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេល មធ្យម ៣-៥ ឆ្នាំ | រយៈពេល វែង លើសពី ៥ ឆ្នាំ | |
| ១. ធ្វើបច្ចុប្បន្នកម្មតួនាទី ភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្រសួងកិច្ចការនារី (JPOs) | - តួនាទី ភារកិច្ច (TOR) ជាក់លាក់សម្រាប់មន្ត្រីនគរបាលយុត្តិធម៌ក្រសួងកិច្ចការនារី (JPOs) ដែលបានធ្វើបច្ចុប្បន្នកម្មនិងផ្សព្វផ្សាយ | - មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី (JPOs) យល់ដឹងកាន់តែច្បាស់ពីតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងការឆ្លើយតបចំពោះស្ត្រីដែលរងគ្រោះដោយអំពើហិង្សា | • ក្រសួងយុត្តិធម៌<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ២. ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលយុត្តិធម៌ក្រសួងកិច្ចការនារី (JPOs) ដើម្បីអភិវឌ្ឍសមត្ថភាព | - ចំនួនមន្ត្រីនគរបាលយុត្តិធម៌ដែលបានបំពេញនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ | - មន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថភាពក្នុងការអនុវត្តការងារស្របតាមតួនាទីនិងភារកិច្ច | • បណ្ឌិត្យសភានគរបាលកម្ពុជា<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងកិច្ចការនារី | | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៣. ធ្វើការប៉ាន់ប្រមាណអំពីសមត្ថភាពភ្នាក់ងារនគរបាលយុត្តិធម៌(JPAs) និងមន្ត្រីនគរបាលយុត្តិធម៌(JPOs) ក្រសួងកិច្ចការនារី និងរៀបចំវគ្គបណ្តុះបណ្តាលកសាងសមត្ថភាព | ក. របាយការណ៍ប៉ាន់ប្រមាណត្រូវបានរៀបចំនិងផ្សព្វផ្សាយ<br>ខ. ចំនួនភ្នាក់ងារនគរបាលយុត្តិធម៌និងមន្ត្រីនគរបាលយុត្តិធម៌ ( JPOs និងJPAs) | - ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី (JPO) មានសមត្ថភាពក្នុងការឆ្លើយតបអំពើហិង្សាលើ | • ក្រសួងកិច្ចការនារី<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងយុត្តិធម៌<br>• ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ដើម្បីឆ្លើយតបនឹងអនុសាសន៍នៃរបាយការណ៍នៃការប៉ាន់ប្រមាណ | ដែលបានទទួលវគ្គបណ្តុះបណ្តាលនិងបានផ្តល់សេវាសមស្របផ្អែកតាម តួនាទីរបស់ខ្លួន និងស្របតាមបទដ្ឋានអប្បបរមាដែលពាក់ព័ន្ធក្នុងការផ្តល់សេវា | ស្ត្រី ប្រកបដោយគុណភាពប្រសិទ្ធភាពនិងទាន់ពេលវេលា | • ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | |
| ៤. រៀបចំកិច្ចប្រជុំប្រចាំឆមាសដើម្បីឆ្លុះបញ្ចាំងការអនុវត្តតួនាទីនិងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ (JPOs) និងភ្នាក់ងារនគរបាលយុត្តិធម៌(JPAs) ក្រសួងកិច្ចការនារី និងកំណត់វិស័យអាទិភាពសម្រាប់សកម្មភាព/កែលម្អ | - របាយការណ៍ស្តីពីការអនុវត្តល្អៗ បញ្ហាប្រឈម និងបទពិសោធក្នុងការអនុវត្ត ផ្អែកតាមការសិក្សារៀនសូត្រពីវគ្គកិច្ចប្រជុំប្រចាំឆមាស ជាមួយនឹងផែនការសកម្មភាព ដើម្បីកែលម្អពេលអនាគត | - ការអនុវត្តល្អត្រូវបានចែករំលែកនិងបញ្ហាប្រឈមនានាត្រូវបានពិភាក្សានិងដោះស្រាយ | • ក្រសួងកិច្ចការនារី<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងយុត្តិធម៌<br>• ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៥. បង្កើនចំនួនមន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌នៅថ្នាក់ក្រោមជាតិ | - ចំនួនមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌នៅថ្នាក់ក្រោមជាតិ មានការកើនឡើង | - ចំនួនមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌នៅថ្នាក់ក្រោមជាតិមានការកើនឡើងក្នុងការឆ្លើយតបអំពើហិង្សាលើស្ត្រីកាន់តែប្រសើរឡើង | • ក្រសួងកិច្ចការនារី<br>• ក្រសួងយុត្តិធម៌<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៦. ពិនិត្យនិងធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សានៃបណ្ឌិត្យសភានគរបាលកម្ពុជា សាកលវិទ្យាល័យការពារជាតិ និងរាជបណ្ឌិត្យសភាវិជ្ជាជីវៈ | - កម្មវិធីសិក្សា (កម្មវិធីសិក្សាជាក់លាក់) ដែលបានពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម | - បទដ្ឋានអប្បរមាស្តីពីសេវា និងគោលការណ៍ណែនាំ ដែលគិតគូរអំពីយេនឌ័រ ត្រូវបានបញ្ចូលនៅក្នុងកម្មវិធី | • បណ្ឌិត្យសភានគរបាលកម្ពុជា<br>• សាកលវិទ្យាល័យការពារជាតិ<br>• រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| តុលាការ ដោយបញ្ចូលបទដ្ឋានអប្បបរមាស្តីពីសេវាកម្មនិងវិធីសាស្ត្រផ្តោតលើជនរងគ្រោះ ដើម្បីទទួលយុត្តិធម៌សម្រាប់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សា | | សិក្សានៃបណ្ឌិត្យសភានគរបាលកម្ពុជា សាកលវិទ្យាល័យការពារជាតិ និងរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ | • ក្រសួងកិច្ចការនារី<br>• ក្រសួងការពារជាតិ | | | | |
| ៧. ផ្តល់ការបណ្តុះបណ្តាលឯកទេសស្តីពី បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ការប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សា សម្រាប់មន្ត្រីនគរបាល យុត្តិធម៌ និងកងរាជអាវុធហត្ថ | ក. ចំនួនមន្ត្រីនគរបាលយុត្តិធម៌ និងកងរាជអាវុធហត្ថដែលបានអភិវឌ្ឍសមត្ថភាពអំពីបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ការប្រឹក្សាជាមូលដ្ឋាន | - មន្ត្រីនគរបាលយុត្តិធម៌និងកងរាជអាវុធហត្ថ អនុវត្តគោលការណ៍ណែនាំដែលបានរៀនពីបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ការប្រឹក្សាជាមូលដ្ឋាន ក្នុងការឆ្លើយតបអំពើហិង្សាលើស្ត្រី | • ក្រសួងកិច្ចការនារី<br>• ក្រសួងការពារជាតិ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៨. ផ្តល់ការបណ្តុះបណ្តាលដល់តុលាការ អាជ្ញាធរមូលដ្ឋាន និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំសង្កាត់ (CCWC) អំពីរបៀបប្រើប្រាស់ អភិក្រមផ្អែកលើសិទ្ធិ និងផ្តល់អាទិភាពលើសុវត្ថិភាពជនរងគ្រោះ អត្ថប្រយោជន៍សេចក្តីសម្រេច រដ្ឋបាល ដីកាការពារ និងការបញ្ជូនករណីអំពើហិង្សាទៅមន្ត្រីនគរបាលយុត្តិធម៌ និងតុលាការ ដើម្បីបន្តការស៊ើប | ក. កញ្ចប់សម្ភារៈបណ្តុះបណ្តាលស្តីពីតួនាទីនៃសេចក្តីសម្រេចរដ្ឋបាល និងដីកាការពារ របៀបប្រើប្រាស់អភិក្រមផ្អែកលើសិទ្ធិ និងផ្តល់អាទិភាពលើសុវត្ថិភាពជនរងគ្រោះ និងការបញ្ជូនករណីអំពើហិង្សាទៅមន្ត្រីនគរបាលយុត្តិធម៌ និងតុលាការដែលបានសម្រេច<br>ខ. ចំនួនតុលាការ អាជ្ញាធរមូល | - សម្ភារៈបណ្តុះបណ្តាលស្តីពីអត្ថប្រយោជន៍សេចក្តីសម្រេចរដ្ឋបាល និងដីកាការពារ និងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសុវត្ថិភាព ត្រូវបានផ្តល់អាទិភាពខ្ពស់ជាងការប្រើប្រាស់នីតិវិធីសម្រុះសម្រួល<br>- តុលាការ អាជ្ញាធរមូលដ្ឋាន និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ | • ក្រសួងកិច្ចការនារី<br>• ក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្នាក់ខេត្ត (PWG-GBV)<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល<br>• ក្រុមការងារឆ្លើយតបពហុ | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អង្កេត/ស៊ើបសួរ | ដ្ឋាន និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ដែលទទួលបានការបណ្តុះបណ្តាល<br>គ. ចំនួនសេចក្តីសម្រេចរដ្ឋបាល និងដីកាការពារដែលបានចេញដោយអាជ្ញាធរពាក់ព័ន្ធ | សង្កាត់ (CCWC) បានបង្កើនចំណេះដឹងអំពីរបៀបប្រើប្រាស់អភិក្រមផ្អែកលើសិទ្ធិ និងផ្តល់អាទិភាពលើសុវត្ថិភាព ជនរងគ្រោះ អត្ថប្រយោជន៍ សេចក្តីសម្រេចរដ្ឋបាល ដីកាការពារ និងការបញ្ជូនករណីអំពើហិង្សាទៅមន្ត្រីនគរបាលយុត្តិធម៌និងតុលាការ ដើម្បីបន្តការស៊ើបអង្កេត/ស៊ើបសួរ | វិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្នាក់ស្រុក (DWG-GBV) | | | | |
| ៩. ពិនិត្យនិងអនុម័តឯកសារជំនួយស្មារតី ស្តីពីគោលការណ៍ណែនាំនៃការអនុវត្តល្អៗសម្រាប់ការសម្រុះសម្រួលជាការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី | - ឯកសារជំនួយស្មារតី ស្តីពីគោលការណ៍ណែនាំនៃការអនុវត្តល្អៗសម្រាប់ការសម្រុះសម្រួល ជាការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី ត្រូវបានសម្រេចនិងអនុវត្ត | - អ្នកផ្តល់សេវាមានសមត្ថភាពក្នុងការសម្រុះសម្រួលករណីអំពើហិង្សាលើស្ត្រី ដោយអនុវត្តគោលការណ៍នៅក្នុងឯកសារជំនួយស្មារតី | • ក្រសួងកិច្ចការនារី<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងមហាផ្ទៃ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ១០. បង្កើតកញ្ចប់ឧបករណ៍បណ្តុះបណ្តាលអំពីឯកសារជំនួយស្មារតី ស្តីពី គោលការណ៍ណែនាំនៃការអនុវត្តល្អៗសម្រាប់ការសម្រុះសម្រួលជាការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី | - កញ្ចប់ឧបករណ៍បណ្តុះបណ្តាលអំពីឯកសារជំនួយស្មារតី ស្តីពីគោលការណ៍ណែនាំនៃការអនុវត្តល្អៗសម្រាប់ការសម្រុះសម្រួលករណីអំពើហិង្សាលើស្ត្រី ដែល | - កញ្ចប់ឧបករណ៍បណ្តុះបណ្តាលអំពីឯកសារជំនួយស្មារតី ស្តីពីគោលការណ៍ណែនាំនៃការអនុវត្តល្អៗសម្រាប់ការសម្រុះសម្រួលករណីអំពើហិង្សាលើស្ត្រី | • ក្រសួងកិច្ចការនារី<br>• ក្រសួងយុត្តិធម៌<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បានអនុម័តនិងអនុវត្ត | ត្រូវបានអនុម័តនិងអនុវត្ត | | | | | |
| ១១. ធ្វើការផ្សព្វផ្សាយនិងផ្តល់វគ្គបណ្តុះបណ្តាលអំពីឯកសារជំនួយស្មារតីស្តីពីគោលការណ៍ណែនាំនៃការអនុវត្តល្អៗសម្រាប់ការសម្រុះសម្រួល ជាការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី | - ចំនួនវគ្គបណ្តុះបណ្តាលនិងអ្នកផ្តល់សេវាដែលបានចូលរួមវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំនៃការអនុវត្តល្អៗសម្រាប់ការសម្រុះសម្រួលករណីអំពើហិង្សាលើស្ត្រី | - អ្នកផ្តល់សេវា ទទួលបានចំណេះដឹង ការសម្រុះសម្រួលវិវាទទាក់ទងនិងករណីអំពើហិង្សា | • ក្រសួងកិច្ចការនារី<br>• ក្រសួងយុត្តិធម៌<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ១២. រៀបចំសិក្ខាសាលាដល់អ្នកអនុវត្តច្បាប់ (នគរបាល កងរាជអាវុធហត្ថ ព្រះរាជអាជ្ញា ចៅក្រមមេធាវី និងអាជ្ញាធរមូលដ្ឋាន) អំពីច្បាប់ដែលពាក់ព័ន្ធ បទដ្ឋាន និងគោលការណ៍ណែនាំនានា អំពីការអនុវត្តយុត្តិធម៌ឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ | ក. ចំនួនដីកាការពារទាក់ទងសំណុំរឿងអំពើហិង្សាលើស្ត្រី<br>ខ. ចំនួនករណីអំពើហិង្សាលើស្ត្រីដែលត្រូវបានធ្វើការចោទប្រកាន់ កាត់ក្តី និងទទួលបានសាលក្រមស្ថាពរ<br>គ. ចំនួនសេចក្តីសម្រេចរបស់តុលាការ | - អ្នកពាក់ព័ន្ធផ្នែកច្បាប់ដែលស្ថិតនៅក្នុងខ្សែចង្វាក់នៃប្រព័ន្ធយុត្តិធម៌ (នគរបាល កងរាជអាវុធហត្ថ ព្រះរាជអាជ្ញា ចៅក្រម) អនុវត្តការងារកាន់តែមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ឯកសារគតិយុត្តដែលមានករណីអំពើហិង្សាលើស្ត្រីនិងផ្អែកលើទស្សនៈយេនឌ័រ | • ក្រសួងកិច្ចការនារី<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងមហាផ្ទៃ<br>• អគ្គស្នងការដ្ឋាននគរបាលជាតិ<br>• ដៃគូពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ១៣. ពិនិត្យនិងតាមដានដំណើរការសវនាការលើករណីអំពើហិង្សាលើស្ត្រីនៅតុលាការ | - របាយការណ៍កាលកំណត់អំពីលទ្ធផលនៃការពិនិត្យ តាមដានដំណើរការសវនាការលើករណីអំពើហិង្សាលើស្ត្រីនៅតុលាការដែលបានចែករំលែកដល់អាជ្ញា | - ការយល់ដឹងកាន់តែប្រសើរឡើងអំពីសាលក្រមតុលាការ បញ្ហាចន្លោះប្រហោង និងបញ្ហាប្រឈមនានានៅក្នុងដំណើរការ | • ក្រសួងកិច្ចការនារី<br>• ក្រសួងយុត្តិធម៌<br>• ក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ធរពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងអំពីសាលក្រមតុលាការ ព្រមទាំងកំណត់រកនិងដោះស្រាយបញ្ហាចន្លោះប្រហោងនិងបញ្ហាប្រឈមនានា | កាត់ក្តីករណីអំពើហិង្សាលើស្ត្រី ត្រូវបានកំណត់ឃើញ | | | | | |
| ១៤. ធ្វើការប៉ាន់ប្រមាណពីការផ្តល់ជំនួយផ្នែកច្បាប់និងអភិវឌ្ឍវិធីសាស្ត្រសមស្របនិងជាក់លាក់សម្រាប់ស្ត្រីរងគ្រោះអាចទទួលបានជំនួយផ្នែកច្បាប់ | - ចំនួនស្ត្រីដែលរងគ្រោះដោយអំពើហិង្សាទទួលបានជំនួយផ្នែកច្បាប់ | - ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រកាន់តែមានលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់តតគិតថ្លៃ | • ក្រសួងកិច្ចការនារី<br>• ក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល | X | | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ១៥. សហការជាមួយសហគ្រាសទីភ្នាក់ងារការងារនិងមុខរបរទីភ្នាក់ងារជ្រើសរើសពលករសហជីពការងារ និងអង្គការដែលធ្វើការងារជាមួយកម្មករ ដើម្បីបង្កើនលទ្ធភាពក្នុងការទទួលបានកិច្ចការពារសម្រាប់កម្មការិនីដែលរងគ្រោះដោយអំពើហិង្សា | - ចំនួនសហគ្រាស ទីភ្នាក់ងារការងារនិងមុខរបរ ទីភ្នាក់ងារជ្រើសរើសពលករ សហជីពការងារ និងអង្គការដែលធ្វើការងារជាមួយកម្មករ ដែលបានចូលរួមឆ្លើយតបអំពើហិង្សាលើស្ត្រី | - អំពើហិង្សាលើស្ត្រី ត្រូវបានដោះស្រាយដោយនិយោជក វិស័យឯកជនហើយកិច្ចការពារអំពើហិង្សាលើស្ត្រីត្រូវបានបង្កើន | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• វិស័យឯកជន<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |
| ១៦. អនុវត្តវិធានការជាក់ស្តែង ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី ក្នុងក្រុមងាយរង | ក. ចំនួនវិធានការអនុវត្តដែលបានដាក់ចេញ សម្រាប់ក្រុមផ្សេងៗ | - ស្ត្រីដែលមានហានិភ័យខ្ពស់ឬងាយរងគ្រោះ មានលទ្ធភាពទទួលសេវាយុត្តិធម៌សម្រាប់ករណីអំពើ | • ក្រសួងមហាផ្ទៃ<br>• គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>• ក្រសួងកិច្ចការនារី | X | X | X | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្រោះ (ស្ត្រីពលករទេសន្តប្រវេសន៍ ស្ត្រីដែលមានពិការភាព ស្ត្រីដែលងាយរងគ្រោះដោយសារមុខរបរ និងផ្សេងៗ) | ខ. របាយការណ៍វឌ្ឍនភាពដែលបានចងក្រងអំពីលទ្ធភាពទទួលបានយុត្តិធម៌ក្នុងករណីពាក់ព័ន្ធនានា | ហិង្សាលើស្ត្រី | • ក្រសួងសុខាភិបាល<br>• ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>• ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល | | | | |

**៣.២.២.៤. សេវាសង្គម**

លទ្ធផលទី៩ **:** បង្កើនលទ្ធភាពសម្រាប់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សា ក្នុងការទទួលបានសេវាសង្គមដែលមានការសម្របសម្រួលប្រកបដោយគុណភាព

សូចនាករលទ្ធផល **:**

៩ក. ចំនួនជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី ដែលមានលទ្ធភាពទទួលបានសេវាសមស្រប មានគុណភាព និងទាន់ពេលវេលា មានការកើនឡើង

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេលមធ្យម ៣-៥ ឆ្នាំ | រយៈពេលវែងលើសពី ៥ឆ្នាំ | |
| ១. ចងក្រងឯកសារទាក់ទងនឹងប្រភេទនៃប្រព័ន្ធដែលអាចទទួលព័ត៌មានទាន់ហេតុការណ៍ អាចរកបាន មានមុខងារសមស្រប និងមានសមត្ថភាព | ក. សៀវភៅមគ្គុទ្ទេសក៍ជាតិមួយមានព័ត៌មានអំពីឈ្មោះស្ថាប័ន ប្រភេទសេវា និងលេខទូរសព្ទទាន់ហេតុការណ៍ ដើម្បីបញ្ជូន | - ប្រព័ន្ធដែលអាចទទួលព័ត៌មានទាន់ហេតុការណ៍ និងប្រព័ន្ធបញ្ជូនជនរងគ្រោះ ត្រូវបានរៀបចំជា | • ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ក្នុងការប្រើប្រាស់ និងផ្ដល់អនុសាសន៍ពីគំរូនៃការអនុវត្តល្អ ផ្អែកលើការសិក្សា | ស្រ្តីដែលរងគ្រោះដោយអំពើហិង្សាទៅទទួលសេវា ផ្សេងៗដែលបានបញ្ជូប់ (ភ្ជាប់ទៅសកម្មភាពទី៦)<br>ខ. ចំនួនព័ត៌មានដែលទទួលបាន និងបញ្ជូនតាមរយៈប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ | ផែនទីសេវា និងដាក់ឱ្យដំណើរការ | | | | | |
| ២. អនុម័ត បទដ្ឋានអប្បបរមាស្ដីពីការផ្ដល់សេវា បង្កើតកញ្ចប់បណ្ដុះបណ្ដាល និងផ្ដល់ការបណ្ដុះបណ្ដាលដល់អ្នកផ្ដល់សេវា អំពីបទដ្ឋានអប្បបរមាដែលពាក់ព័ន្ធសម្រាប់ការផ្ដល់សេវា (បទដ្ឋានអប្បបរមាស្ដីពីការផ្ដល់សេវាចាំបាច់ គោលការណ៍ណែនាំស្ដីពីការបញ្ជូន និងបទដ្ឋានអប្បបរមាសម្រាប់ការផ្ដល់ប្រឹក្សាជាមូលដ្ឋាន និងបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀត) | ក. ចំនួនកញ្ចប់បណ្ដុះបណ្ដាលដែលបានបង្កើត<br>ខ. ចំនួនអ្នកផ្ដល់សេវា ដែលបានទទួលការបណ្ដុះបណ្ដាលអំពីបទដ្ឋានអប្បបរមាដែលពាក់ព័ន្ធសម្រាប់ការផ្ដល់សេវា<br>គ. ភាគរយនៃការកើនឡើង នៃការផ្ដល់សេវាប្រកបដោយគុណភាព (ស៊ីចង្វាក់គ្នាជាមួយនឹងបទដ្ឋានសេវាអប្បបរមា) | - សេវាសង្គមសម្រាប់ជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី ដែលមានគុណភាពប្រសើរឡើង លទ្ធភាពទទួលបាន អាចស្វែងរកបាន និងដែលមានលក្ខណៈសមស្រប ដោយផ្អែកទៅតាមបទដ្ឋានអប្បបរមាដែលពាក់ព័ន្ធសម្រាប់ការផ្ដល់សេវា ត្រូវបានអនុវត្ត | • ក្រសួងកិច្ចការនារី<br>• ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៣. ពិនិត្យនិងធ្វើបច្ចុប្បន្នកម្ម ឧបករណ៍ប្រមូលទិន្នន័យនិង ប្រព័ន្ធគ្រប់គ្រងករណី ដោយពិចារណាលើជម្រើសនានាដូចជា កម្មវិធីទូរសព្ទដៃឬប្រព័ន្ធផ្សេងៗ ដើម្បីងាយស្រួលប្រើ | ក. ចំនួនឧបករណ៍និងប្រព័ន្ធប្រមូលទិន្នន័យ ដែលបានបង្កើតឡើង | - ការអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងករណី រាប់បញ្ចូលទាំងការបញ្ជូនទៅរកសេវានានា មានភាពប្រសើរឡើង | • ក្រសួងកិច្ចការនារី<br>• ក្រសួង ស្ថាប័ន<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ប្រាស់នៅថ្នាក់ក្រោមជាតិ<br>៤. រៀបចំនិងផ្តល់កញ្ចប់បណ្តុះបណ្តាលដល់អាជ្ញាធរនិងអ្នកផ្តល់សេវាពាក់ព័ន្ធ អំពីការគ្រប់គ្រងករណីនិងដំណើរការប្រមូលទិន្នន័យ<br>៥. ផ្តល់ការបំប៉នសមត្ថភាពនិងចុះត្រួតពិនិត្យ ដើម្បីអនុវត្តប្រព័ន្ធនោះ | ខ. ចំនួនកញ្ចប់បណ្តុះបណ្តាលសម្រាប់អាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវានានា | - អាជ្ញាធរមូលដ្ឋាននិងអ្នកផ្តល់សេវាពាក់ព័ន្ធ ទទួលបានការបណ្តុះបណ្តាលអំពីដំណើរការគ្រប់គ្រងករណី និងប្រព័ន្ធប្រមូលទិន្នន័យ | | | X | | |
| ៦. បង្កើតសៀវភៅមគ្គុទ្ទេសក៍ស្តីពីប្រភេទសេវាសម្រាប់អំពើហិង្សាលើស្ត្រី ដែលអាចធ្វើបច្ចុប្បន្នកម្មអំពីអ្នកផ្តល់សេវាពាក់ព័ន្ធ សេវាដែលបានផ្តល់ និងព័ត៌មានទំនាក់ទំនងនានាសម្រាប់ស្ត្រីរងគ្រោះដោយអំពើហិង្សា | - ចំនួនសៀវភៅមគ្គុទ្ទេសក៍ស្តីពីប្រភេទសេវាដែលបានបង្កើតថ្មី និងបានធ្វើបច្ចុប្បន្នកម្ម | - សៀវភៅមគ្គុទ្ទេសក៍ស្តីពីប្រភេទសេវាដែលបានបង្កើតនិងធ្វើបច្ចុប្បន្នកម្មត្រូវបានផ្សព្វផ្សាយនិងអនុវត្ត | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងកិច្ចការនារី<br>• ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៧. ផ្តល់ការបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាអំពីការអនុវត្តល្អៗ ក្នុងការផ្តល់សេវាដល់ក្រុមងាយរងគ្រោះ រួមទាំងហានិភ័យនៃអំពើហិង្សាលើស្ត្រី បទពិសោធនៃការទទួលរងនូវការមាក់ងាយ និងការរើសអើង និងតម្រូវការជាក់លាក់របស់ក្រុមងាយរងគ្រោះ | ក. ចំនួនអ្នកផ្តល់សេវាដែលទទួលបានការបណ្តុះបណ្តាល<br>ខ. ភាគរយនៃការបង្កើនគុណភាពសេវាដែលអាចរកបាន លទ្ធភាពទទួលបាន និងសមស្រប | - លទ្ធភាពដែលអាចស្វែងរកបាន ទទួលបាន និងភាពសមស្របសម្រាប់សេវាសំខាន់ៗសម្រាប់ក្រុមស្ត្រីដែលមានហានិភ័យខ្ពស់ និងងាយរងគ្រោះ ត្រូវបានបង្កើន | • ក្រសួងកិច្ចការនារី<br>• ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៨. កំណត់និងពង្រីកនូវគំរូអនុវត្តន៍ល្អៗ | - ចំនួនគំរូនៃការអនុវត្តល្អៗ ក្នុង | - ជនរងគ្រោះ កាន់តែទទួល | • ក្រសួងកិច្ចការនារី | X | X | | រាជរដ្ឋាភិបាល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សម្រាប់ការផ្តល់សេវាដូចជា ទីជម្រកសុវត្ថិភាពបណ្តោះអាសន្ន រយៈពេលខ្លី និងវែង (កំណត់ អភិវឌ្ឍពិធីសារ អនុវត្ត) | ការផ្តល់សេវា ដែលបានកំណត់ និងពង្រីកបន្ថែម | បានទីជម្រកសុវត្ថិភាព ការគាំទ្រផ្នែកផ្លូវចិត្ត ការផ្គត់ផ្គង់សម្ភារៈ និងសេវាចាំបាច់ផ្សេងៗទៀត | • ក្រសួងសុខាភិបាល<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | និងដៃគូអភិវឌ្ឍ |
| ៩. គាំទ្រការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីជំនាញនៅតាមក្រសួង ស្ថាប័ន ក្នុងការធ្វើសកម្មភាពទាក់ទងនឹងការគាំទ្រមតិលើការបង្កើនថវិកា ដើម្បីផ្តល់សេវាឬបង្កើតកិច្ចសន្យាសម្រាប់ការផ្តល់សេវាចាំបាច់នានា | - ចំនួនមន្ត្រីជំនាញនៅតាមក្រសួង ស្ថាប័ន ដែលបានចូលរួមអភិវឌ្ឍសមត្ថភាពក្នុងការធ្វើសកម្មភាពទាក់ទងនឹងការគាំទ្រមតិ ដើម្បីបង្កើនថវិកា | - សមត្ថភាពរបស់មន្ត្រីជំនាញនៅតាមក្រសួង ស្ថាប័ន ក្នុងការធ្វើសកម្មភាពទាក់ទងនឹងការគាំទ្រមតិ ដើម្បីបង្កើនថវិកា មានភាពប្រសើរឡើង | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ក្រសួងកិច្ចការនារី<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ១០. បញ្ចូលកម្មវិធីសិក្សាទាក់ទងនឹងអំពើហិង្សាលើស្ត្រី ទៅក្នុងកម្មវិធីសិក្សានៃសាលាភូមិន្ទរដ្ឋបាល មហាវិទ្យាល័យចិត្តសាស្ត្រ មហាវិទ្យាល័យសង្គម និងដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ (DMC) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រឹះស្ថានអប់រំវិស័យសុខាភិបាល។ | - ចំនួនកម្មវិធីសិក្សាដែលបានដាក់បញ្ចូលការសិក្សាទាក់ទងនឹងអំពើហិង្សាលើស្ត្រី | - អ្នកជំនាញដែលពាក់ព័ន្ធបានបង្កើនការយល់ដឹងអំពីវិធីសាស្ត្រផ្តោតលើជនរងគ្រោះ ដើម្បីផ្តល់កិច្ចអន្តរាគមន៍ដល់ស្ត្រីដែលទទួលរងគ្រោះដោយអំពើហិង្សាលើស្ត្រី | • ក្រសួងអប់រំ យុវជន និងកីឡា<br>• ក្រសួងសុខាភិបាល<br>• ក្រសួងកិច្ចការនារី<br>• សាកលវិទ្យាល័យភូមិន្ទភ្នំពេញ<br>• សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ១១. បង្កើតបញ្ជីត្រួតពិនិត្យ សម្រាប់ | ក. បញ្ជីត្រួតពិនិត្យបទដ្ឋានអប្ប | - តួនាទីត្រួតពិនិត្យ តាមដាន | • ក្រសួងកិច្ចការនារី | | X | | រាជរដ្ឋាភិបាល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បទដ្ឋានអប្បបរមាដែលពាក់ព័ន្ធសម្រាប់ការផ្តល់សេវា និងអភិវឌ្ឍសមត្ថភាពក្នុងការប្រើប្រាស់បញ្ជីត្រួតពិនិត្យ ដើម្បីអនុវត្តតួនាទីត្រួតពិនិត្យ តាមដាន ដើម្បីធានាបាននូវគុណភាពនៃសេវា (របកគំហើញនានាភ្ជាប់ទៅការត្រួតពិនិត្យតាមដាន និងវាយតម្លៃ)។ | បរមា ត្រូវបានបង្កើត<br><br>ខ. ចំនួននៃដំណើរការត្រួតពិនិត្យតាមដានដែលបានបញ្ចប់បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់សេវាដែលពាក់ព័ន្ធ | របស់ក្រសួងកិច្ចការនារី ក្នុងការលើកកម្ពស់ការផ្តល់សេវាចាំបាច់ប្រកបដោយគុណភាព សម្រាប់ស្ត្រី ជាជនរងគ្រោះដោយអំពើហិង្សា ត្រូវបានពង្រឹង | • ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | | | | និងដៃគូអភិវឌ្ឍ |

**៣.២.៣. យុទ្ធសាស្ត្រទី៣ : ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ**

**លទ្ធផល : ច្បាប់និងគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ត្រូវបានតាក់តែងឡើងដោយផ្អែកលើទស្សនៈយេនឌ័រ និងការពារសិទ្ធិជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី និងជនប្រព្រឹត្តត្រូវទទួលខុសត្រូវចំពោះមុខច្បាប់**

៣.២.៣.១. ការពិនិត្យឡើងវិញលើបទដ្ឋានគតិយុត្ត

លទ្ធផលទី១០ : ក្របខ័ណ្ឌគតិយុត្តនៅកម្ពុជាក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី ត្រូវបានពង្រឹង

សូចនាករលទ្ធផល : ច្បាប់និងបទប្បញ្ញត្តិនៅកម្ពុជាទាក់ទងនឹងអំពើហិង្សាលើស្ត្រី ត្រូវបានពង្រឹង

១០ក. ច្បាប់និងបទប្បញ្ញត្តិនៅកម្ពុជាទាក់ទងនឹងអំពើហិង្សាលើស្ត្រី ត្រូវបានពង្រឹង

១០ខ. ចំនួននៃក្របខ័ណ្ឌគតិយុត្តដែលមានភាពប្រសើរឡើងសម្រាប់ការអនុវត្តជាមួយជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី

១០គ. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ត្រូវបានពិនិត្យ ហើយសិក្សាវាយតម្លៃនៃការអនុវត្តច្បាប់នេះ

១០ឃ. ឯកសារសេចក្តីពន្យល់គ្រប់ជ្រុងជ្រោយអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ត្រូវបានអភិវឌ្ឍនិងផ្សព្វផ្សាយ

១០ង. គោលនយោបាយនានាទាក់ទងនឹងការបៀតបៀនផ្លូវភេទ ត្រូវបានអភិវឌ្ឍ ជាមួយនឹងនិយមន័យគ្រប់ជ្រុងជ្រោយអំពីការបៀតបៀនផ្លូវភេទនៅទីសាធារណៈនិងឯកជន

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេលមធ្យម ៣-៥ ឆ្នាំ | រយៈពេលវែងលើសពី ៥ ឆ្នាំ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១. បង្កើតក្រុមការងារជំនាញដើម្បីធ្វើការពិនិត្យនិងវិភាគលើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ | - ចំនួនមន្ត្រីជំនាញដែលចូលរួមក្នុងក្រុមការងារ | - ក្រុមការងារជំនាញដើម្បីធ្វើការពិនិត្យនិងវិភាគលើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះនឹងត្រូវបានបង្កើតឡើងដោយមានការចូលរួមពីបណ្តាក្រសួងពាក់ព័ន្ធ ដោយប្រើប្រាស់អភិក្រមពហុវិស័យ | • ក្រសួងមហាផ្ទៃ<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងកិច្ចការនារី<br>• គណៈមេធាវីកម្ពុជា<br>• ភាគីពាក់ព័ន្ធ | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ២. ផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិភាគច្បាប់ ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិនិងក្របខ័ណ្ឌពាក់ព័ន្ធ (អនុសញ្ញាCEDAW និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ) | - ចំនួនមន្ត្រីដែលជាសមាជិកក្រុមការងារជំនាញ ដែលបានចូលរួមវគ្គបណ្តុះបណ្តាល | - មន្ត្រីបច្ចេកទេសដែលពាក់ព័ន្ធ មានសមត្ថភាពក្នុងការវិភាគឧបករណ៍សម្រាប់ការអនុវត្តគោលនយោបាយ និងធនធាន ដូចជា ក្របខ័ណ្ឌនិងអនុសញ្ញាអន្តរជាតិ | • ក្រសួងកិច្ចការនារី<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងយុត្តិធម៌<br>• គណៈមេធាវីកម្ពុជា<br>• ភាគីពាក់ព័ន្ធ | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៣. ធ្វើការវិភាគអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដើម្បីកំណត់នូវវិស័យសំខាន់ៗស្របតាមបទដ្ឋានជាតិនិងអន្តរជាតិ និងដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់ធ្វើវិសោធនកម្មច្បាប់នេះ ដោយផ្អែកលើលទ្ធផល | ក. របាយការណ៍នៃការវិភាគលើមាត្រានៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ<br><br>ខ. ចំនួនកិច្ចប្រជុំមន្ត្រីជំនាញ ក្រុមការងារជំនាញ និងប្រជុំ | - ផែនការសកម្មភាពមួយត្រូវបានរៀបចំ អនុវត្តដើម្បីធ្វើវិសោធនកម្មច្បាប់ កំណែទម្រង់ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ | • ក្រសួងកិច្ចការនារី<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងយុត្តិធម៌<br>• គណៈមេធាវីកម្ពុជា<br>• ភាគីពាក់ព័ន្ធ | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| នៃការវិភាគនេះ។ | ពិគ្រោះយោបល់នានា ក្នុងការពិភាក្សាលើការវិភាគលើមាត្រានៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ | | | | | | |
| ៤. វាយតម្លៃលើការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ | - លទ្ធផលអំពីវឌ្ឍនភាពនៃការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ត្រូវបានរៀបចំចងក្រងនិងផ្សព្វផ្សាយ | - មាត្រាមួយចំនួននៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ នឹងត្រូវបានស្នើសុំធ្វើវិសោធនកម្ម<br>- ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះត្រូវបានធ្វើវិសោធនកម្មនិងអនុវត្តប្រកបដោយប្រសិទ្ធភាព | • ក្រសួងមហាផ្ទៃ<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងកិច្ចការនារី<br>• គណៈមេធាវីកម្ពុជា<br>• ភាគីពាក់ព័ន្ធ | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៥. ពិនិត្យនិងធ្វើបច្ចុប្បន្នកម្មសេចក្ដីពន្យល់ ដើម្បីឱ្យការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះមានប្រសិទ្ធភាព | - ឯកសារស្ដីពីសេចក្ដីពន្យល់ដើម្បីឱ្យការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានរៀបចំនិងផ្សព្វផ្សាយ | - ឯកសារសេចក្ដីពន្យល់មានភាពច្បាស់លាស់ ក្នុងការឆ្លើយតបទៅនឹងច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ គឺអាចស្វែងរកបានសម្រាប់គ្រប់អ្នកពាក់ព័ន្ធ | • ក្រសួងមហាផ្ទៃ<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងកិច្ចការនារី<br>• គណៈមេធាវីកម្ពុជា<br>• ភាគីពាក់ព័ន្ធ | X | | | |
| ៦. បង្កើតនិងអនុវត្តគោលការណ៍ | - គោលការណ៍ណែនាំស្ដីពីការ | - គោលការណ៍ណែនាំស្ដីពី | • ក្រសួងមហាផ្ទៃ | | | X | រាជរដ្ឋាភិបាល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ណែនាំស្តីពីការបង្ការ ទប់ស្កាត់ការបៀតបៀនផ្លូវភេទ | បង្ការ ទប់ស្កាត់ការបៀតបៀនផ្លូវភេទ ត្រូវបានបង្កើតនិងអនុវត្ត | ការបង្ការ ទប់ស្កាត់បៀតបៀនផ្លូវភេទ ត្រូវបានយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត | • ក្រសួងយុត្តិធម៌<br>• ក្រសួងកិច្ចការនារី<br>• គណៈមេធាវីកម្ពុជា<br>• ភាគីពាក់ព័ន្ធ | | | | និងដៃគូអភិវឌ្ឍ |
| ៧. ធ្វើការត្រួតពិនិត្យទៅលើនិយាមអន្តរជាតិ (រួមទាំង ILO)ដើម្បីអភិវឌ្ឍនិយមន័យនៃអំពើរុកកួនផ្លូវភេទ ឱ្យមានលក្ខណៈកាន់តែគ្រប់ជ្រុងជ្រោយ កាតព្វកិច្ចអប្បបរមារបស់និយោជកនិងមន្ត្រីរបស់ក្រសួងស្ថាប័ន និងបង្កើតយន្តការដាក់ពាក្យបណ្តឹងនិងរៀបចំសកម្មភាព ដើម្បីដោះស្រាយសម្រាប់ករណីអំពើហិង្សាលើស្ត្រី | ក. ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ពីស្ថាប័នពាក់ព័ន្ធលើគោលការណ៍ណែនាំស្តីពីការបង្ការទប់ស្កាត់អំពើរុកកួនផ្លូវភេទ<br>ខ. ចំនួននិយមន័យ កាតព្វកិច្ច និងយន្តការនានាដែលបានបង្កើតនិងកំណត់ | - គោលនយោបាយទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការត្រូវបានបង្កើតឡើងយោងតាមគោលការណ៍ណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអនុវត្តច្បាប់ការងារដែលហាមឃាត់អំពើរុកកួនផ្លូវភេទ | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងព័ត៌មាន<br>• ភាគីពាក់ព័ន្ធ | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

**៣.២.៣.២. ការពិនិត្យលើគោលនយោបាយនិងការពង្រឹងស្ថាប័ន**

លទ្ធផលទី១១ក: ក្របខ័ណ្ឌគោលនយោបាយ ត្រូវបានកែលម្អនិងសម្របសម្រួលបានយ៉ាងល្អ ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីប្រកបដោយប្រសិទ្ធភាព។

សូចនាករលទ្ធផល:

១១ក. ចំនួនគោលនយោបាយតាមវិស័យដែលពាក់ព័ន្ធ ត្រូវបានពិនិត្យ

១១ខ. ក្រសួង ស្ថាប័នពាក់ព័ន្ធមានផែនការសកម្មភាពនិងថវិកាសម្រាប់អនុវត្តសកម្មភាពទាក់ទងនឹងអំពើហិង្សាលើស្ត្រី

១១គ. ផែនការសកម្មភាពប្រចាំឆ្នាំត្រូវបានបង្កើត និងថវិកាប្រចាំឆ្នាំសម្រាប់ការអនុវត្ត សម្រាប់គោលនយោបាយដែលបានពិនិត្យរួច

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|

| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេលមធ្យម ៣-៥ ឆ្នាំ | រយៈពេលវែងលើសពី ៥ ឆ្នាំ | |
|---|---|---|---|---|---|---|---|
| ១. ពិនិត្យឡើងវិញលើគោលនយោបាយ ច្បាប់ស្តីពីការងារ និងការអនុវត្តនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនលទ្ធភាពក្នុងការទទួលបានកិច្ចការពារ និងសេវាគាំទ្រនានា ចំពោះក្រុមងាយរងគ្រោះ (គោលនយោបាយទេសន្តរប្រវេសន៍ការងារ គោលនយោបាយស្តីពីជនជាតិដើមភាគតិច គោលការណ៍ណែនាំស្តីពីគ្មានការបៀតបៀននៅកន្លែងធ្វើការ...) | - ច្បាប់ គោលនយោបាយ និងបទប្បញ្ញត្តិនានាដែលត្រូវបានបង្កើតនិងកែសម្រួលក្នុងការឆ្លើយតប ដោយបានគិតគូរអំពីយេនឌ័រនិងដើម្បីការពារសិទ្ធិស្ត្រីនិងក្មេងស្ត្រីរងគ្រោះដោយអំពើហិង្សា | - គោលនយោបាយតាមវិស័យដែលពាក់ព័ន្ធនឹងកិច្ចអន្តរាគមន៍លើករណីអំពើហិង្សាលើស្ត្រី ត្រូវបានពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ដើម្បីធ្វើការកែលម្អ | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងសុខាភិបាល<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២. ពិនិត្យឡើងវិញលើគោលនយោបាយពាក់ព័ន្ធ (ឧទាហរណ៍: ទេសន្តរប្រវេសន៍ ជួញដូរមនុស្ស អំពើហិង្សាលើស្ត្រី) ដើម្បីធានាឱ្យមានការចូលរួម ដោយមានការសម្របសម្រួលសម្រាប់ការអភិវឌ្ឍការគាំទ្រនានាដល់ស្ត្រីពលករទេសន្តរប្រវេសន៍ | - ចំនួនគោលនយោបាយនិងកម្មវិធីដែលបានបញ្ចូលស្ត្រីពលករទេសន្តរប្រវេសន៍ | - គោលនយោបាយនិងកម្មវិធីសំខាន់ៗ ត្រូវបានបង្កើតនិងគាំទ្រដល់ស្ត្រីពលករទេសន្តរប្រវេសន៍ | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងមហាផ្ទៃ<br>• គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>• ក្រសួងកិច្ចការនារី<br>• ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | X | X | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

**៣.២.៤. យុទ្ធសាស្ត្រទី៤ : ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ**

**គោលបំណង : ដើម្បីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងគ្រប់ជ្រុងជ្រោយមួយសម្រាប់ប្រមូល តាមដាន វិភាគ និងរាយការណ៍ទិន្នន័យអំពើហិង្សាលើស្ត្រីដោយផ្អែកលើភស្តុតាងច្បាស់លាស់**

**៣.២.៤.១. ក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ**

លទ្ធផលទី១២ : ក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ និងប្រព័ន្ធប្រមូលនិងតាមដានទិន្នន័យគ្រប់ជ្រុងជ្រោយ ត្រូវបានបង្កើតឡើង ដែលរួមបញ្ចូលទាំងទិន្នន័យទទួលបានពីការសិក្សាស្តីពីអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី

សូចនាករលទ្ធផល :

១២ក. តួអង្គសំខាន់ៗប្រមូលនិងផ្តល់ទិន្នន័យរដ្ឋបាលដល់អ្នកពាក់ព័ន្ធឱ្យបានទាន់ពេលវេលា ចំពោះអំពើហិង្សាលើស្ត្រី។

| សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុក | ស្ថាប័នទទួលខុសត្រូវ | រយៈពេល | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ១-២ ឆ្នាំ | រយៈពេលមធ្យម ៣-៥ ឆ្នាំ | រយៈពេលវែងលើសពី ៥ ឆ្នាំ | |
| ១. បង្កើតក្របខ័ណ្ឌតាមដាននិងវាយតម្លៃ សម្រាប់ផែនការសកម្មភាពជាតិស្តីពី ទប់ស្កាត់អំពើហិង្សាលើ | - ឯកសារបទដ្ឋានអំពីក្របខ័ណ្ឌតាមដាននិងវាយតម្លៃនៃការអនុវត្តផែនការសកម្មភាពជាតិ | - ផែនការតាមដាននិងវាយតម្លៃត្រូវបានបង្កើតនិងដាក់ឱ្យអនុវត្ត ដោយបញ្ចូល | • លេខាធិការដ្ឋាន TWGG-GBV<br>• ដៃគូពាក់ព័ន្ធនិងអង្គការ | X | | | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ស្ត្រី | ស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រីត្រូវ បានបង្កើតនិងអនុវត្ត | ព័ត៌មានគ្រប់គ្រាន់ដើម្បីតាមដានការអនុវត្តផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី<br>- បទដ្ឋាននិងឧបករណ៍សម្រាប់ការតាមដាននិងវាយតម្លៃ ត្រូវបានអនុវត្ត រួមទាំងការរាយការណ៍ | សង្គមស៊ីវិល | | | | |
| ២. បង្កើតប្រព័ន្ធប្រមូលទិន្នន័យនិងឧបករណ៍នៅតាមវិស័យផ្សេងៗ ឱ្យកាន់តែប្រសើរឡើងប្រកបដោយគុណភាព មានសង្គតិភាព និងស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ | - ប្រព័ន្ធប្រមូលទិន្នន័យនៅតាមវិស័យផ្សេងៗ និងឧបករណ៍ជាក់លាក់ប្រកបដោយបរិយាបន្ន ត្រូវបានបង្កើតនិងអនុវត្ត | - ប្រព័ន្ធប្រមូលទិន្នន័យនិងឧបករណ៍នៅតាមវិស័យផ្សេងៗ ត្រូវបានកែលម្អឱ្យប្រសើរឡើងប្រកប ដោយគុណភាព មានសង្គតិភាព និងស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ | • លេខាធិការដ្ឋាន TWGG-GBV<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៣. បង្កើតនិងអនុវត្តផែនការស្តីពីក្របខ័ណ្ឌត្រួតពិនិត្យ តាមដាន វាយតម្លៃ និងការអនុវត្ត NAPVAW រួមទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ក. ផែនការសកម្មភាពរួមស្តីពីការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត NAPVAW ត្រូវបានបង្កើតនិងអនុវត្ត<br>ខ. ប្រព័ន្ធប្រមូលទិន្នន័យថ្នាក់ក្រោមជាតិ ដើម្បីត្រួតពិនិត្យតាមដានការអនុវត្ត | - ការអនុវត្ត NAPVAW បានតាមដាន ត្រួតពិនិត្យរួមគ្នាជាប្រចាំ<br>- ទិន្នន័យអំពីស្ថានភាពនៃអំពើហិង្សាលើស្ត្រីនិងវឌ្ឍនភាពនៃផែនការសកម្មជាតិស្តីពីការទប់ស្កាត់អំពើ | • លេខាធិការដ្ឋាន TWGG-GBV<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | X | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | NAPVAW ត្រូវបានបង្កើត និងអនុវត្ត<br>គ. ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃការអនុវត្ត NAPVAW ត្រូវបានធ្វើឡើង | ហិង្សាលើស្ត្រី ឆ្នាំ ២០១៩-២០២៣ នេះ ត្រូវបាន ប្រមូល វិភាគ និងចែករំលែក | | | | | |
| ៤. ធ្វើការសិក្សាស្រាវជ្រាវ អំពីស្ថានភាពអំពើហិង្សាលើស្ត្រីក្នុងក្រុមងាយរងគ្រោះនិងអំពីបញ្ហាថ្មីៗនិងបញ្ហាដែលកំពុងកើតឡើង ព្រមទាំងអំពើហិង្សាលើស្ត្រី | ក. ការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាលើស្ត្រី ក្នុងក្រុមងាយរងគ្រោះ ត្រូវបានបញ្ចប់និងផ្សព្វផ្សាយ<br><br>ខ. ការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធអំពីបញ្ហាដែលកំពុងកើតឡើង ត្រូវបានធ្វើឡើង និងផ្សព្វផ្សាយ | - របាយការណ៍នៃការសិក្សាស្រាវជ្រាវ ត្រូវបានផ្សព្វផ្សាយនិងអនុវត្តតាមអនុសាសន៍នានា | • លេខាធិការដ្ឋាន TWGG-GBV<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល | X | X | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |
| ៥. ដាក់បញ្ចូលជំពូកស្ដីពីអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាពីដៃគូស្និទ្ធស្នាល ទៅក្នុងអង្កេតស្ដីពីប្រជាសាស្ត្រនិងសុខភាព (CDHS) ២០២០ | ក. ជំពូកស្ដីពីអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាពីដៃគូស្និទ្ធស្នាល ត្រូវបានដាក់បញ្ចូលក្នុង CDHS ២០២០<br><br>ខ. វិធីសាស្ត្ររបស់អង្គការ WHO ត្រូវបានបញ្ចូល ក្នុងCDHS ២០២០ | - ទិន្នន័យប្រេវ៉ាឡង់ ត្រូវបានប្រមូលតាមរយៈ CDHS ដើម្បីស្វែងយល់អំពីការប្រែប្រួល អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងឥរិយាបថក្នុងការស្វែងរកជំនួយក្នុងរយៈពេល១២ខែចុងក្រោយនិងពេញមួយជីវិត | • លេខាធិការដ្ឋាន TWGG-GBV<br>• ដៃគូពាក់ព័ន្ធនិងអង្គការសង្គមស៊ីវិល<br>• វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | X | | | រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ |

## ៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

ដើម្បីលើកកម្ពស់សមភាពយេនឌ័រ រាជរដ្ឋាភិបាលបានទទួលស្គាល់ពីសារៈសំខាន់នៃការទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅក្នុងសង្គមកម្ពុជានិងបានរៀបចំឱ្យមានច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះនិងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ដើម្បីជួយការពារនិងផ្តល់ជំនួយដល់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព គុណភាព និងទាន់ពេលវេលា។

ដើម្បីអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវបង្កើនការយល់ដឹងពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះនិងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត រួមទាំងបញ្ហាប្រឈមដែលជនរងគ្រោះបានជួបប្រទះក្នុងការទទួលយកសេវាកិច្ចការពារផ្នែកច្បាប់។ ការយល់ដឹងនេះអាចធ្វើឱ្យការឆ្លើយតបក្នុងការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានលក្ខណៈសមស្របនិងទាន់ពេលវេលា។ បញ្ហាដែលជនរងគ្រោះតែងប្រឈមក្នុងការទទួលយកសេវា គឺដោយសារហេតុផលដូចខាងក្រោម៖

ក. ការយល់ដឹងរបស់អាជ្ញាធរនិងប្រជាពលរដ្ឋអំពីច្បាប់ នៅមានកម្រិត ហើយការផ្សព្វផ្សាយអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក៏មិនទាន់បានទូលំទូលាយនៅឡើយ ជាពិសេសនៅតំបន់ដាច់ស្រយាល។

ខ. ការទប់ស្កាត់និងការផ្តល់កិច្ចអន្តរាគមន៍ចំពោះអំពើហិង្សាលើស្ត្រីពីមន្ត្រីអនុវត្តច្បាប់និងអ្នកពាក់ព័ន្ធមួយចំនួន នៅមិនទាន់ពេលវេលានៅឡើយ ដោយសារខ្វះធនធាននិងជំនាញនៅមានកម្រិត។

គ. ចំណាត់ការរឿងក្តីដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីមួយចំនួន ប្រើប្រាស់រយៈពេលយូរ។

ឃ. ការស្នើសុំមេធាវីសម្រាប់ជួយការពារក្តីឱ្យជនរងគ្រោះជាស្ត្រីក្រីក្រ នៅមានជួបឧបសគ្គ ដោយសារចំនួនមេធាវីនៅមានកម្រិត ជាពិសេសនៅតាមតំបន់ដាច់ស្រយាល ហើយនីតិវិធីស្នើសុំប្រើពេលយូរ នាំឱ្យការងារមិនអាចឆ្លើយតបបានទាន់ពេលវេលាស្របនឹងសេចក្តីត្រូវការរបស់ជនរងគ្រោះ។

ង. មាត្រាមួយចំនួនក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ នៅមិនទាន់អាចឆ្លើយតបឱ្យបានគ្រប់ជ្រុងជ្រោយស្របតាមស្ថានភាពបច្ចុប្បន្ននៅឡើយ។

រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការធ្វើកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌និងកំពុងបន្តបោះជំហានទៅមុខលើទិសដៅត្រឹមត្រូវនិងប្រកបដោយយុទ្ធសាស្ត្រ ក្នុងការពង្រឹងស្ថាប័ននិងកិច្ចការពារដល់ប្រជាពលរដ្ឋ ជាពិសេសគឺផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើស្ត្រីនិងកុមារនៅកម្រិតសហគមន៍ ។

ព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ថ្មីៗជាច្រើន រួមមានក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ផ្សេងៗទៀត ដែលធានានូវសិទ្ធិស្មើភាពគ្នារវាងស្ត្រីនិងបុរសស្របនឹងបទដ្ឋានអន្តរជាតិនិងស៊ីចង្វាក់នឹងច្បាប់នៃបណ្តាប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជានៅលើពិភពលោក។ នៅក្នុងការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ កម្ពុជាទទួលបានជោគជ័យអាស្រ័យដោយ៖

ក. កិច្ចសហការដោយមានការគាំទ្រនិងការលើកទឹកចិត្តរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងជនរងគ្រោះផ្ទាល់ ដែលបានផ្តល់ព័ត៌មានទាន់ពេលវេលានិងចូលរួមផ្តល់កិច្ចអន្តរាគមន៍បានឆាប់រហ័ស។

ខ. មន្ត្រីអនុវត្តច្បាប់និងអាជ្ញាធរមានសមត្ថកិច្ចបានជួយជនរងគ្រោះ ប្រកបដោយឆន្ទៈ ការប្តេជ្ញាចិត្តនិងការទទួលខុសត្រូវខ្ពស់ ដើម្បីធានាថា ជនរងគ្រោះអាចទទួលបានសេវាផ្នែកច្បាប់ សង្គម សុខភាព និងអប់រំ ប្រកបដោយភាពសមស្របនិងទាន់ពេលវេលា។

គ. ប្រជាពលរដ្ឋបានចូលរួមវេទិកាសាធារណៈនៅតាមសាលារៀននិងសហគមន៍ ដោយផ្តល់នូវសំណួរចម្លើយ និងត្រូវបានដោះស្រាយបញ្ហាតាមស្ថានភាពជាក់ស្តែង។

ឃ. សារអប់រំជាក់លាក់ត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ជួយឱ្យយុវជនបានចូលរួមផ្តល់យោបល់និងផ្លាស់ប្តូរបទពិសោធគ្នាទៅវិញទៅមក ដើម្បីផ្លាស់ប្តូរផ្នត់គំនិតនិងឥរិយាបថ ហើយគាំទ្រថា អំពើហិង្សាលើស្ត្រី គឺជាអំពើដែលមិនអាចទទួលយកបានឡើយ។

ដើម្បីចូលរួមឱ្យសកម្មខ្លាំងក្លាថែមទៀតក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រីឱ្យដល់កម្រិតអប្បបរមា និងលើកកម្ពស់នូវវប្បធម៌អហិង្សានិងភាពសុខដុមរមនានៅក្នុងគ្រួសារ សហគមន៍ និងសង្គម អនុសាសន៍ដូចខាងក្រោមត្រូវបានដាក់ចេញ៖

ក. ពិនិត្យឡើងវិញនូវខ្លឹមសារមាត្រាមួយចំនួននៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នភាពស្របតាមស្ថានភាពជាក់ស្តែង។

ខ. ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់ដៃគូពាក់ព័ន្ធសំខាន់ៗនៅក្នុងខ្សែចង្វាក់យុត្តិធម៌ (អាជ្ញាធរមូលដ្ឋាន នគរបាល ចៅក្រម ព្រះរាជអាជ្ញា មេធាវី) ដើម្បីមានចំណេះដឹងគ្រប់គ្រាន់ សម្រាប់ដោះស្រាយករណីអំពើហិង្សាលើស្ត្រីនិងការផ្តល់កិច្ចការពារដល់សិទ្ធិរបស់ជនរងគ្រោះ ផ្អែកលើទស្សនៈយេនឌ័រនិងទាន់ពេលវេលា និងជំរុញការទទួលខុសត្រូវរបស់ជនប្រព្រឹត្តនៅចំពោះមុខច្បាប់។

គ. ពន្លឿននីតិវិធីដើម្បីឱ្យជនរងគ្រោះដោយអំពើហិង្សា ជាពិសេសសម្រាប់ស្ត្រីក្រីក្រ អាចទទួលបានតំណាងផ្នែកច្បាប់នៅពេលដែលត្រូវការ ដោយសហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន។

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៩-២០២៣ គឺជាផែនការមួយសម្រាប់ការអនុវត្តរយៈពេលខ្លី ដែលតម្រូវឱ្យដៃគូទាំងអស់រួមចំណែកដល់ការអនុវត្តផែនការនេះ ដើម្បីសម្រេចបានជោគជ័យរួម។ ដូច្នេះ ការស្នើសុំធ្វើវិសោធនកម្មលើមាត្រានៃច្បាប់ចាំបាច់មួយចំនួន ការរៀបចំតាក់តែងបទប្បញ្ញត្តិថ្មី និងការធ្វើឱ្យប្រសើរឡើងនូវសេចក្តីប្រកាសអន្តរក្រសួង ត្រូវផ្តួចផ្តើមឡើងដោយមានការយល់ដឹងពេញលេញ ហើយសកម្មភាពទាំងនេះនឹងត្រូវបន្តសម្រាប់ការអនុវត្តរយៈពេលវែង។

## ៥. គម្រោងចំណាយ

ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ នេះ ត្រូវប្រើប្រាស់ថវិកាជាតិ ដែលតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវគ្រោងថវិកានៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាមីក្រសួងស្ថាប័ននីមួយៗ ដោយវិភាជតាមលទ្ធភាពថវិកាប្រចាំឆ្នាំនិងថវិកាដែលបានមកពីដៃគូអភិវឌ្ឍ ផ្នែកឯកជន សង្គមស៊ីវិល និងសប្បុរសជន។

## ៦. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីឱ្យផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ អនុវត្តបានដោយជោគជ័យនិងសម្រេចបានលទ្ធផលតាមការរំពឹងទុកនិងប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព តម្រូវឱ្យមានការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ។ ការអនុវត្តនេះគួរបញ្ចូលនូវយន្តការនានាដូចខាងក្រោម៖

ក. លេខាធិការដ្ឋានក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) ដែលមានតួនាទីជាស្ថាប័នចម្បងក្នុងការតាមដាននិងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣។

ខ. ប្រព័ន្ធប្រមូលទិន្នន័យដើម្បីតាមដានការអនុវត្តផែនការសកម្មភាពជាតិស្ដីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី នឹងត្រូវបានបង្កើតឡើងដោយមានការសហការជាមួយបណ្ដាក្រសួងពាក់ព័ន្ធនិងសង្គមស៊ីវិល ដើម្បីធ្វើជាឧបករណ៍សម្រាប់ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍។ ប្រព័ន្ធនេះនឹងផ្ដល់ឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនូវធនធានសម្រាប់អភិវឌ្ឍនិងវិភាគគោលនយោបាយ និងអាចកែលម្អការអនុវត្តក្នុងការផ្ដល់សេវា។ ប្រព័ន្ធនេះនឹងរំលេចពីការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់ ក៏ដូចជាបញ្ហាប្រឈមក្នុងការអនុវត្ត ដែលប្រការនេះនឹងរួមចំណែកលើកកម្ពស់តម្លាភាពនិងគណនេយ្យភាពក្នុងការអនុវត្ត។

បន្ថែមលើនេះ ទិន្នន័យផ្សេងទៀត រួមមានទិន្នន័យអំពីអត្រាប្រេវ៉ាឡង់ តាមរយៈការអង្កេតស្ដីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា (CDHS) នឹងវាស់ស្ទង់អំពីវឌ្ឍនភាពរបស់ផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ ។

ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃនៃផែនការសកម្មភាពជាតិស្ដីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី នឹងដាក់បញ្ចូលនូវរបាយការណ៍សកម្មភាពប្រចាំឆ្នាំ របាយការណ៍វាយតម្លៃនៃការអនុវត្តពាក់កណ្ដាលអាណត្តិ និងការវាយតម្លៃចុងក្រោយ។

# ៧. សេចក្ដីសន្និដ្ឋាន

ផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ ត្រូវបានរៀបចំឡើងផ្អែកលើកត្តាជោគជ័យ បទពិសោធ និងមេរៀនដែលបានមកពីការអនុវត្តផែនការសកម្មភាពជាតិស្ដីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨។ កិច្ចខិតខំប្រឹងប្រែងបង្ការ ទប់ស្កាត់ដែលបានដាក់ចេញនៅក្នុងផែនការសកម្មភាពជាតិនេះ មានគោលបំណងលើកកម្ពស់ការសម្របសម្រួលនិងអភិក្រមគ្រប់ជ្រុងជ្រោយដែលផ្ដោតសំខាន់លើការផ្លាស់ប្ដូរជាវិជ្ជមាននៅតាមទីកន្លែងនិងស្ថានភាពផ្សេងៗ។ នៅក្នុងផ្នែកកិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ មានគោលបំណងកសាងភាពជោគជ័យផ្អែកលើការអភិវឌ្ឍបទដ្ឋាននានានិងការកែលម្អកិច្ចសម្របសម្រួលឱ្យកាន់តែប្រសើរឡើង ការអភិវឌ្ឍសមត្ថភាពដៃគូពាក់ព័ន្ធសំខាន់ៗក្នុងកិច្ចសហការផ្ដល់សេវាជួយជនរងគ្រោះឱ្យកាន់តែល្អប្រសើរជាងមុន ដោយផ្អែកតាមអភិក្រមផ្ដោតលើជនរងគ្រោះនិងកិច្ចអន្តរាគមន៍ប្រកបដោយបរិយាបន្ន។ ផែនការនេះនឹងផ្ដោតការយកចិត្តទុកដាក់លើការពង្រឹងការយល់ដឹងការអនុវត្ត និងការជំរុញការអនុវត្តច្បាប់និងគោលនយោបាយនានានៅថ្នាក់ក្រោមជាតិ។ ច្បាប់និងគោលនយោបាយ នឹងត្រូវបានពិនិត្យឡើងវិញ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនិងចំណុចខ្វះខាត ដោយផ្អែកលើការអនុវត្តជាក់ស្ដែងនិងស្របតាមបទដ្ឋានជាតិនិងអន្តរជាតិ។ ក្រៅពីនេះ ប្រព័ន្ធប្រមូលនិងតាមដានទិន្នន័យជាក់លាក់មួយ នឹងត្រូវបានបង្កើតនិងដាក់ឱ្យប្រើប្រាស់ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣។

# សទ្ទានុក្រម

**១- អំពើហិង្សាទាក់ទងនឹងយេនឌ័រ**

សំដៅដល់អំពើហិង្សាដោយផ្ទាល់លើស្ត្រី ដោយសារតែពួកគាត់ជាភេទស្រីនិងមានស្ថានទម្ងន់នៃផលប៉ះពាល់ផ្សេងៗគ្នា។ អំពើហិង្សារាប់បញ្ចូលទាំងសកម្មភាពទាំងឡាយណាដែលធ្វើឱ្យមានរបួសស្នាមដល់រាងកាយ ផ្លូវចិត្ត ឬគ្រោះថ្នាក់ផ្លូវភេទ ឬបង្កការឈឺចាប់ និងការគំរាមកំហែងដោយ សកម្មភាព ការបង្ខិតបង្ខំ និងការដកហូតសិទ្ធិសេរីភាព ជាដើម។

**២- អំពើហិង្សាលើស្ត្រី**

សំដៅដល់សកម្មភាពទាំងឡាយនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបណ្តាលឱ្យឬអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់រូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត ឬការឈឺចាប់ដល់ស្ត្រី រួមទាំងការគំរាមកំហែងដោយសកម្មភាព ការបង្ខិតបង្ខំ ឬការដកហូតសិទ្ធិសេរីភាពតាមទំនើងចិត្ត ហើយអាចកើតឡើងនៅតាមទីសាធារណៈឬនៅក្នុងជីវិតឯកជន។ អំពើហិង្សាលើស្ត្រីត្រូវបានផ្តល់នូវនិយមន័យក្នុងលក្ខណៈគ្របដណ្តប់ទូលំទូលាយ ហើយក៏មិនកំណត់ត្រឹមអ្វីដូចបានបង្ហាញខាងក្រោមនេះទេ៖

- ក. អំពើហិង្សាលើរូបរាងកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលកើតឡើងនៅក្នុងគ្រួសារ ដូចជាការវាយដំ ការរំលោភបំពានផ្លូវភេទលើកូនស្រីនៅក្នុងគ្រួសារ អំពើហិង្សាទាក់ទងនឹងជំនូនពេលរៀបការ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ការកាត់ផ្នែកខ្លះនៃសរីរាង្គភេទរបស់ស្ត្រី និងប្រពៃណីផ្សេងៗទៀតដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ត្រី អំពើហិង្សាដែលបង្កឡើងដោយបុគ្គលដែលមិនមែនជាប្តីប្រពន្ធ និងអំពើហិង្សាដែលទាក់ទងនឹងការកេងប្រវ័ញ្ចផ្សេងៗ។
- ខ. អំពើហិង្សាលើរូបរាងកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលកើតឡើងនៅក្នុងសហគមន៍ទូទៅ រួមមានការរំលោភសេពសន្ថវៈ ការរំលោភបំពានផ្លូវភេទ ការប្រទូស្តកេរ្តិ៍ខ្មាស និងការបំភិតបំភ័យនៅកន្លែងធ្វើការ គ្រឹះស្ថានអប់រំ និងកន្លែងផ្សេងទៀត ការជួញដូរស្ត្រី និងពេស្យាចារដោយបង្ខំ។
- គ. អំពើហិង្សាលើរូបរាងកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលបានប្រព្រឹត្ត ឬលើកលែងទោសដោយរដ្ឋ នៅពេលណាដែលអំពើហិង្សាបែបនោះកើតឡើង។

**៣- ការបង្ការ ទប់ស្កាត់**

សំដៅដល់ការបង្ការ ទប់ស្កាត់អំពើហិង្សាលើស្ត្រី គឺមានពីរកម្រិត ដូចជាការបង្ការ ទប់ស្កាត់បឋមនិងការបង្ការ ទប់ស្កាត់កម្រិតបន្ទាប់។ ការបង្ការ ទប់ស្កាត់បឋមនៃអំពើហិង្សាលើស្ត្រី រាប់បញ្ចូលរាល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដែលធ្វើឡើងដើម្បីបញ្ឈប់មិនឱ្យមានអំពើហិង្សាកើតឡើង តាមរយៈការដោះស្រាយនូវមូលហេតុដែលជាឫសគល់នៃអំពើ

ហិង្សាដើម្បីកាត់បន្ថយឱកាសនៃអំពើហិង្សាដែលអាចកើតឡើងនៅពេលអនាគត។ អន្តរាគមន៍បង្ការ ទប់ស្កាត់បឋមតម្រូវឱ្យមានការកំណត់គោលដៅទៅលើក្រុមជាក់លាក់ដែលមានហានិភ័យខ្ពស់ក្នុងការប្រើប្រាស់និង/ឬជួបប្រទះអំពើហិង្សានាពេលអនាគតជាមួយនឹងយុទ្ធសាស្ត្រដែលលើកកម្ពស់ការផ្លាស់ប្តូរជាវិជ្ជមាន លើផ្នត់គំនិត អត្តចរិត ឥរិយាបថ ជំនឿ ការអនុវត្ត និងបទដ្ឋានសង្គម។

ការបង្ការ ទប់ស្កាត់កម្រិតបន្ទាប់ តម្រូវឱ្យមានការអភិវឌ្ឍប្រព័ន្ធនៃការផ្តល់សេវានិងការឆ្លើយតបមួយដើម្បីកាត់បន្ថយហានិភ័យនៃអំពើហិង្សាទាំងនោះ ជាមួយនឹងយុទ្ធសាស្ត្រនៃកិច្ចអន្តរាគមន៍ដំបូងនិងការផ្តល់កិច្ចអន្តរាគមន៍ដែលកាត់បន្ថយផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី រួមទាំងដើម្បីដោះស្រាយជាមួយជនប្រព្រឹត្ត។

**៤_ កិច្ចអន្តរាគមន៍**

សំដៅដល់កម្មវិធីឬសកម្មភាពដែលត្រូវបានរៀបចំឡើងដើម្បីបង្ការទប់ស្កាត់អំពើហិង្សាឬកាត់បន្ថយការកើតឡើងវិញឬផលប៉ះពាល់នៃអំពើហិង្សា។

**៥_ ការឆ្លើយតប**

សំដៅដល់ការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី ដែលជាសកម្មភាពនៃប្រព័ន្ធសេវាសុខាភិបាល នគរបាល និងយុត្តិធម៌ និងសេវាសង្គមដើម្បីឆ្លើយតបនឹងអំពើហិង្សា តាមរយៈការធ្វើឱ្យការផ្តល់សេវាដែលមានការសម្របសម្រួលប្រកបដោយគុណភាពនិងធ្វើឱ្យជនប្រព្រឹត្តទទួលខុសត្រូវ។

**៦_ ការចិញ្ចឹមកូនបែបវិជ្ជមាន**

សំដៅដល់ការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សារួមទាំងការមិនអើពើ ដោយផ្តោតទៅលើគោលដៅយូរអង្វែង ការផ្តល់ភាពកក់ក្តៅនិងដែនកំណត់ ការយល់អំពីការគិតនិងអារម្មណ៍ និងការដោះស្រាយបញ្ហារបស់កូនៗ។ ការចិញ្ចឹមកូនបែបវិជ្ជមាន ជំរុញឱ្យមានការប្រាស្រ័យទាក់ទងនិងការសន្ទនាគ្នាទៅវិញទៅមក។

**៧_ សមភាពយេនឌ័រ**

សំដៅដល់សិទ្ធិ ការទទួលខុសត្រូវ និងកាលានុវត្តន៍នានាដោយស្មើភាពគ្នារបស់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។ សមភាព មិនមានន័យថាស្ត្រីនិងបុរសត្រូវក្លាយមកជាមនុស្សតែមួយនោះទេ។ ប៉ុន្តែសិទ្ធិការទទួលខុសត្រូវ និងកាលានុវត្តន៍ភាពនានារបស់ស្ត្រីនិងបុរស ក៏នឹងមិនអាស្រ័យលើថាតើពួកគេកើតមកជាមនុស្សប្រុសឬមនុស្សស្រីនោះដែរ។ សមភាពយេនឌ័រ មានន័យថា ផលប្រយោជន៍ តម្រូវការ និងអាទិភាពនានាទាំងរបស់ស្ត្រីនិងបុរសត្រូវបានគេយកមកពិចារណានិងទទួលស្គាល់ភាពដោយឡែកផ្សេងៗគ្នារបស់ពួកគេ។ សមភាពរវាងស្ត្រីនិងបុរសត្រូវបានចាត់ទុកជាសិទ្ធិមនុស្ស បុរេលក្ខខណ្ឌនិងសូចនាករសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែលផ្តោតលើមនុស្ស។

**៨_ សមធម៌យេនឌ័រ**

សំដៅដល់ដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រីនិងបុរសសំដៅឲ្យមានសមភាពយេនឌ័រ។ ដើម្បីធានាបាននូវភាពយុត្តិធម៌ត្រូវ

តែមានវិធានការដើម្បីលុបបំបាត់នូវឧបសគ្គរាំងស្ត្រីនិងបុរស មិនឲ្យចែករំលែកតួនាទីសង្គមបានត្រឹមត្រូវ។ ការចាត់វិធានការទាំងនោះគឺសំដៅបំបាត់គម្លាតជាក់ស្តែងនៅជ្រុងណាមួយ ដែលរារាំងមិនឲ្យស្ត្រីឬបុរសបានទទួលឋានៈនិងផលប្រយោជន៍ពីការអភិវឌ្ឍស្មើៗគ្នា។

**៩- អំពើហិង្សាពីដៃគូស្និទ្ធស្នាល** សំដៅដល់លើឥរិយាបថទាំងឡាយណាដែលរំខានដល់ទំនាក់ទំនង និងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់រូបរាង្គកាយ ផ្លូវចិត្ត និងផ្លូវភេទ នៃទំនាក់ទំនងនេះ។ អំពើហិង្សាពីដៃគូស្និទ្ធស្នាល គឺជាទម្រង់មួយនៃអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទនិងរួមបញ្ចូលទាំងអំពើហិង្សាលើរូបរាងកាយដូចជាការទះ ការទាត់ ការដាល់ និងការវាយដំ អំពើហិង្សាផ្លូវភេទ ដូចជាការបង្ខិតបង្ខំឱ្យរួមភេទនិងការបង្ខិតបង្ខំខាងផ្លូវភេទតាមទម្រង់ផ្សេងៗទៀត ការរំលោភបំពានផ្លូវចិត្តដូចជា ការជេរប្រមាថ ការរំលោភបំពាន ការធ្វើឱ្យមានភាពអាម៉ាស់ ការបំភិតបំភ័យ ការគំរាមកំហែងដែលបង្កជាគ្រោះថ្នាក់ ការគំរាមកំហែងយកកុមារទៅឆ្ងាយ និងការគ្រប់គ្រងឥរិយាបថដូចជា ការបំបែកនរណាម្នាក់ចេញពីគ្រួសារ និងមិត្តភក្តិ ការត្រួតពិនិត្យឥរិយាបថរបស់ពួកគេ ការរឹតបន្តឹងលទ្ធភាព ក្នុងការទទួលបានធនធានហិរញ្ញវត្ថុ ការងារ ការអប់រំ និងការថែទាំសុខភាពរបស់ពួកគេ។

**១០- អំពើហិង្សាក្នុងគ្រួសារ** សំដៅដល់លើអំពើហិង្សាដែលកើតមាននិងអាចកើតមានទៅលើប្តីឬប្រពន្ធ កូនក្នុងបន្ទុក ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះនិងក្នុងបន្ទុកគ្រួសារ។

**១១- បទរុកគួនខាងផ្លូវភេទ** សំដៅដល់អំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ។

**១២- បទប្រទូស្តកេរខ្មាស** សំដៅដល់អំពើប៉ះពាល់ ស្ទាបអង្អែលកេរភេទឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃតែបុគ្គលនេះមិនស្ម័គ្រផងទេ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួនឬទៅលើតតិយបុគ្គលក្នុងគោលបំណងធ្វើឱ្យរំជួលឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។

**១៣- បទដ្ឋានសង្គម** សំដៅដល់ផ្នត់គំនិតមួយចំនួនកើតមាននៅក្នុងសង្គមជាយូរមកហើយដែលរើសអើងនិងដាក់បន្ទុកលើស្ត្រី។ ឧទាហរណ៍ នៅពេលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារភរិយាត្រូវស៊ូទ្រាំ អត់ធ្មត់ មិនត្រូវប្រកែកជាមួយស្វាមី ហើយមិនត្រូវយករឿងនេះទៅប្រាប់អ្នកដទៃឡើយព្រោះជារឿងគ្រួសារ។ឧទាហរណ៍មួយទៀត អំពីហិង្សាជាបញ្ហារបស់គ្រួសារគេ ដូច្នេះអ្នកដទៃមិនត្រូវលូកដៃបញ្ហារបស់គេឡើយ។

# ឯកសារពិគ្រោះ


១- UN Women(២០១៨)៖ បញ្ឈប់អំពើហិង្សាលើស្ត្រី បានចូលពិនិត្យក្នុងវិបសាយថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨ http://www.unwomen.org/en/what- we-do/ending-violence-against-women.

២- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ(២០១៥)- *ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ២០១៤*

៣- របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៨

៤- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ(២០១៥)- *ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ២០១៤*

៥- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (២០១៥)- *ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ២០១៤*

៦- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (២០១៥)- *ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ២០១៤*

៧- ក្រសួងកិច្ចការនារី (២០១៥)- *ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាពនិងបទពិសោធក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា* រាជធានីភ្នំពេញ

៨- ក្រសួងកិច្ចការនារី (២០១៤)- *ការស្ទង់មតិស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា* រាជធានីភ្នំពេញ

៩- ក្រសួងកិច្ចការនារី (២០១៤)- *ការស្ទង់មតិស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា* រាជធានីភ្នំពេញ

១០- ក្រសួងកិច្ចការនារី (២០១៤)- *ការស្ទង់មតិស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា* រាជធានីភ្នំពេញ

១១- Astury, J., Walji F. (២០១៣)- ការទទួលរងគ្រោះផ្ទួនៗគ្នាបីដង : *អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបទពិសោធរបស់ស្ត្រីពិការដែលរងគ្រោះ*

១២- Mauney (២០១៥)- *អំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងសហគមន៍ជនជាតិភាគតិចក្នុងខេត្តរតនគីរី រាជធានីភ្នំពេញ៖ អង្គការយែរអន្តរជាតិប្រចាំកម្ពុជា*